ក N°56/16→31/7/2016

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


| | | |
|---|---|---|
| ១៤-០៧-២០១៦ | -ព្រះរាជក្រម នស/រកម/០៧១៦/០០៩ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី យុត្តិធម៌អនីតិជន | ៦៥២៧ |


### ២~ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៣-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧១៧ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **តូច ឡាវីណូវ៉ង់** តែងតាំង និងផ្តល់ឋានៈឯកឧត្តម **យិន វីរៈ** ជាជំនួយការសម្តេច **នរោត្តម សិរីវុឌ្ឍ** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ អគ្គនាយក | ៦៥៦៦ |
| ១៣-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧១៨ ស្តីពី ការតែងតាំង និងផ្តល់ឋានៈទីប្រឹក្សា និងជំនួយការឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ០៣ រូប | ៦៥៦៧ |
| ១៣-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧១៩ ស្តីពី ការតែងតាំង និងផ្តល់ឋានៈទីប្រឹក្សា និងជំនួយការឯកឧត្តម **សំ ព្រហ្មនា** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ០៣ រូប | ៦៥៦៨ |
| ១៣-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧២០ ស្តីពី ការតែងតាំង និងផ្តល់ឋានៈទីប្រឹក្សា និងជំនួយការសម្តេចរាជបុត្រីព្រះរៀម **នរោត្តម បុប្ផាទេវី** សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ០៣ រូប | ៦៥៦៩ |
| ១៣-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧២១ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ម៉េង គីមលី** តែងតាំង និងផ្តល់ឋានៈលោកជំទាវ **ពិត សុភក្តិ** ជាទីប្រឹក្សាឯកឧត្តម **ពិត តាំងសាន** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ រដ្ឋលេខាធិការ | ៦៥៧០ |
| ១៤-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧២២ ស្តីពី ការតែងតាំងឯកឧត្តម **ខៀវ បូរិន** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ម៉េង សាវុធ** ជាជំនួយការអមក្រសួងបរិស្ថាន មានឋានៈស្មើ អគ្គនាយក | ៦៥៧១ |
| ១៤-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧២៣ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **គោគ សំអុន** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ | ៦៥៧២ |

| | | |
|---|---|---|
| ១៤-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧២៤ ស្តីពី ការតែងតាំងលោក **តូច ហ៊ត** និង លោក **វណ្ណ សុខហេង** ជា ឧកញ៉ា | ៦៩៧៣ |
| ១៤-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧២៥ ស្តីពី ការប្តូរ និងតម្លើងប្រភេទក្របខ័ណ្ឌ ស្របតាម អតីតភាពការងារ និងកម្រិតសញ្ញាបត្រ ជាករណីពិសេសដល់លោក **ប៉ូយ សីឡាំង** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៦៩៧៤ |
| ១៤-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧២៦ ស្តីពី ការលុបឈ្មោះឯកឧត្តម **អ៊ុច សេង** ឧត្តមមន្ត្រីថ្នាក់លេខ ៥ អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ចេញពីក្របខ័ណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ដោយមូលហេតុសាមីខ្លួនទទួលមរណៈភាព | ៦៩៧៥ |
| ១៤-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧២៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក និងលោកស្រី ចំនួន ៥៩ រូប | ៦៩៧៦ |
| ១៥-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧២៨ ស្តីពី ការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ ចំពោះសព ឧបាសិកា **ប៊ិច ឡឹង** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សប្ញទ្ធិ | ៦៩៧៩ |
| ១៥-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧២៩ ស្តីពី ការតែងតាំងអស់លោក ចំនួន ៥ រូប ជា ឧកញ៉ា | ៦៩៨០ |
| ១៥-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៣០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **កៅ ប៊ុនសុង** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាល ជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ | ៦៩៨១ |
| ១៥-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៣១ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ២ រូប | ៦៩៨២ |
| ១៥-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៣២ ស្តីពី ការតម្លើងថ្នាក់ ជាករណីពិសេស ដល់ លោកជំទាវ **ស៊ឹម ខេងខាំ** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសុខាភិបាល | ៦៩៨៣ |
| ១៥-៧-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៣៣ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ជូននាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ៧ រូប | ៦៩៨៤ |

១៩-៧-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៣៤ ស្តីពី ការតែងតាំងឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **អានតុន ការ៉ាគា** (ANTON CARAGEA) ប្រធានក្រុមប្រឹក្សាទេសចរណ៍ និងពាណិជ្ជកម្មអឺរ៉ុប ជាឯកអគ្គរាជទូតសុឆន្ទៈទេសចរណ៍កម្ពុជា ៦៥៨៥

២២-៧-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៣៧ ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ចំនួន ០៤ រូប ៦៥៨៦

២២-៧-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៣៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់លោកវរសេនីយ៍ឯក **ច្រាក់ រ៉ូហ្សា** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៦៥៨៧

២២-៧-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៣៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម ឧកញ៉ា លោកជំទាវ អស់លោក លោកស្រី និងកញ្ញា ចំនួន ៤៦ រូប ៦៥៨៨

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

*-អនុក្រឹត្យលេខ ១៥៥ អនក្រ.បក មិនទាន់បានទទួល*

១៨-៧-២០១៦ -អនុក្រឹត្យលេខ ១៥៦ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា ៦៥៩០

១៩-៧-២០១៦ -អនុក្រឹត្យលេខ ១៥៧ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ៦៦១៣

២៥-៧-២០១៦ -អនុក្រឹត្យលេខ ១៥៨ អនក្រ.បក ស្តីពី ការធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅក្នុងបុរីសណ្ឋាគារអង្គរសៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប ៦៦២០

១៨-៧-២០១៦ -អនុក្រឹត្យលេខ ៨១៨ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៦៦២២

១៨-៧-២០១៦ -អនុក្រឹត្យលេខ ៨១៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៦២៤

១៨-៧-២០១៦ -អនុក្រឹត្យលេខ ៨២០ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៦៦២៦

១៨-៧-២០១៦ -អនុក្រឹត្យលេខ ៨២១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៦២៨

១៨-៧-២០១៦ -អនុក្រឹត្យលេខ ៨២២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៦៣០

១៨-៧-២០១៦ -អនុក្រឹត្យលេខ ៨២៣ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៦៦៣២

២២-៧-២០១៦ -អនុក្រឹត្យលេខ ៨២៤ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៦៦៣៣

២៧-៧-២០១៦ -អនុក្រឹត្យលេខ ៨២៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៦៣៤

២៧-៧-២០១៦ -អនុក្រឹត្យលេខ ៨២៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៦៣៦

## ២-សេចក្តីសម្រេច

២០-៧-២០១៦ -សេចក្តីសម្រេចលេខ ៧១ សសរ ស្តីពី ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៦៦៣៧

*-សេចក្តីសម្រេចលេខ ៧២ សសរ មិនទាន់បានទទួល*

២៧-៧-២០១៦ -សេចក្តីសម្រេចលេខ ៧៣ សសរ ស្តីពី ការតែងតាំងអនុប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៦៦៣៩

២៧-៧-២០១៦ -សេចក្តីសម្រេចលេខ ៧៤ សសរ ស្តីពី ការបំពេញបន្ថែម និងផ្លាស់ប្តូរសមាជិកក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៦៦៤១

## III-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៣-៦-២០១៦ -ប្រកាសលេខ ៧៤០ សហវ.ប្រក ស្តីពី ការបង្កើតក្រុមការងារអន្តរក្រសួងរៀបចំនីតិវិធីគ្រប់គ្រងចំណូលពីកម្រៃសេវាធ្វើដំណើរ ៦៦៤៣

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

# ច្បាប់

## ស្ដីពី

# យុត្តិធម៌អនីតិជន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

## មាត្រា ១.- គោលបំណង

ច្បាប់នេះមានគោលបំណង៖

- ធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស
- គាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍
- ធានាការពារផលប្រយោជន៍សង្គមនិងសហគមន៍ ។

## មាត្រា ២.- គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្តិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន ។

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ និងច្បាប់ដោយឡែកផ្សេងទៀត ត្រូវយកមកអនុវត្ត លើកលែងតែក្នុងករណីដែលមានចែងនៅក្នុងច្បាប់នេះ ។

## មាត្រា ៣.- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើករណីអនីតិជនប្រព្រឹត្តបទល្មើស ។

## មាត្រា ៤.- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

១- យុត្តិធម៌អនីតិជន សំដៅដល់ការការពារសិទ្ធិអនីតិជនតាមរយៈយន្តការ វិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងអនុវត្តដោយហ្មត់ចត់ ព្រមទាំងវិធាននៃការកំណត់ទោសក្នុងករណីអនីតិជនប្រព្រឹត្តបទល្មើស ។

២- អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់បុគ្គល ឬស្ថាប័នដែលអនុវត្តដោយស្របច្បាប់នូវមុខងាររបស់ខ្លួនដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជន ។

៣- អនីតិជន សំដៅដល់ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ។

៤- អនីតិជនត្រូវការកិច្ចការពារ និងថែទាំ សំដៅដល់អនីតិជនដែលត្រូវការកិច្ចការពារ និងថែទាំ ដោយមូលហេតុអនីតិជននោះគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬគ្មានការថែទាំ និងគ្រប់គ្រងត្រឹមត្រូវពីសំណាក់អ្នកតំណាងដែលច្បាប់បានកំណត់ ហើយកំពុងប្រឈមនឹងសភាពគ្រោះថ្នាក់ ឬរងការរំលោភបំពាន ឬបង្ហាញការគំរាមកំហែងដល់សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន ។

៥- អ្នកតំណាងដែលច្បាប់បានកំណត់ សំដៅដល់អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅ ។

៦- អ្នកទំនុកបម្រុង សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលត្រូវបានជ្រើសរើសដោយអនីតិជន ឬដោយអាជ្ញាធរមានសមត្ថកិច្ច និងមានការយល់ព្រមពីអនីតិជនឲ្យទទួលខុសត្រូវក្នុងការទំនុកបម្រុងខ្លួនក្នុងអំឡុងពេលអនុវត្តនីតិវិធីដែលមានចែងក្នុងច្បាប់នេះ ។

៧- នីតិវិធីកុមារមេត្រី សំដៅដល់ដំណើរការ និងនីតិវិធីដែលពាក់ព័ន្ធនឹងការលើកទឹកចិត្តឲ្យអនីតិជនចូលរួមក្នុងរឿងក្តី តាមរយៈការប្រើប្រាស់ភាសានិងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់បាន និងក្នុងបរិយាកាសដែលផ្តល់ឲ្យអនីតិជននូវសុវត្ថិភាព សន្តិសុខ សិទ្ធិ និងតម្រូវការជាមូលដ្ឋាន ។

៨- របាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន សំដៅដល់របាយការណ៍ស្តីពីស្ថានភាពទូទៅរបស់អនីតិជន និងការផ្តល់យោបល់វាយតម្លៃផ្សេងៗដែលធ្វើឡើងដោយភ្នាក់ងារសង្គមកិច្ច ។

៩- ភ្នាក់ងារសង្គមកិច្ច សំដៅដល់មន្ត្រីរបស់ក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្តុះបណ្តាលជំនាញផ្នែកកុមារ និងច្បាប់ពាក់ព័ន្ធនឹងអនីតិជន ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១០- មណ្ឌលយុវនីតិសម្បទា សំដៅដល់មណ្ឌលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ផ្តល់សេវាការពារ ថែទាំ អប់រំ ស្តារនីតិសម្បទា និងសមាហរណកម្មដល់អនីតិជន ។

## ជំពូកទី ២
## គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជន

### មាត្រា ៥.- គោលការណ៍ជាមូលដ្ឋាន

គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឲ្យមានការគោរព គោលការណ៍ដូចតទៅ ៖

- ត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេស ធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា
- ត្រូវប្រព្រឹត្តប្រកបដោយមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរទៅលើអនីតិជន
- ត្រូវផ្តល់ឱកាសឲ្យអនីតិជនសម្តែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន
- ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី
- ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្តន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន
- មិនត្រូវរើសអើងចំពោះអនីតិជន មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ឋានៈសង្គម ធនធាន ដើមកំណើតជាតិ និន្នាការនយោបាយ ឬស្ថានភាពឯទៀត
- មិនត្រូវប្រើខ្នោះ និងឧបករណ៍ផ្សេងៗទៀតដែលប៉ះពាល់ដល់បូរណភាពរូបរាងកាយរបស់អនីតិជន លើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះដែលវិធានការទាំងឡាយមិនអាចអនុវត្តបាន ឬគ្មានប្រសិទ្ធភាព
- មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក តាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជន
- មិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អនីតិជន និងដែលនាំឲ្យបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជន ហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារក្នុងការទទួលបាននូវការអប់រំ ការងារ ការស្នាក់នៅ ឬសុវត្ថិភាព ។ ការផ្សព្វផ្សាយរឿងក្តីអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា ដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនឡើយ
- សន្មតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

**មាត្រា ៦.- សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី**

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌ និងវដ្តប្បវេណីរបស់អនីតិជន

**មាត្រា ៧.- ការទទួលខុសត្រូវព្រហ្មទណ្ឌ**

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។

### មាត្រា ៨.- ការទទួលខុសត្រូវរដ្ឋប្បវេណី

បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៧៤៥ (អសមត្ថភាពក្នុងការទទួលខុសត្រូវ) និងមាត្រា ៧៤៦ (ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ) នៃជំពូកទី ១៦ (អំពើអនីត្យានុកូល) ក្នុងគន្ថីទី ៥ (កិច្ចសន្យាសំខាន់ៗ និងអំពើអនីត្យានុកូល)នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការទទួលខុសត្រូវរដ្ឋប្បវេណីរបស់អនីតិជន ។

### មាត្រា ៩.- ការកំណត់អាយុ

អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស ។

កស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត ។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ កស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកកស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន ។

ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ ។

## ជំពូកទី ៤
## ជំនួយផ្នែកសេវាសង្គមកិច្ច

### មាត្រា ១០.- ការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច

ការតែងតាំង ការទទួលស្គាល់ និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ចជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

បែបបទនៃការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច។

### មាត្រា ១១.- ភ្នាក់ងារសង្គមកិច្ច

ភ្នាក់ងារសង្គមកិច្ចមានភារកិច្ចជាអាទិ៍ ៖

- ជួបអនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី ជាពិសេស នៅដំណាក់កាលដំបូងនៃនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ និងនៅក្នុងពន្ធនាគារ ដើម្បីប្រមូលព័ត៌មានវាយតម្លៃ និងផ្តល់សេវាបន្ទាន់ដល់អនីតិជន

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- ប្រមូលព័ត៌មានស្តីពីស្ថានភាពគ្រួសារ អាកប្បកិរិយា ប្រវត្តិអប់រំ ការសិក្សា លក្ខខណ្ឌដែលទាក់ទងនឹងការរស់នៅ ការរីកលូតលាស់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលទាក់ទងនឹងកម្រិតយល់ដឹង បញ្ញាអារម្មណ៍ ផ្លូវចិត្ត សង្គមរបស់អនីតិជន ដើម្បីរៀបចំ និងផ្តល់របាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនជូនចៅក្រម អយ្យការ និងតុលាការ
- ផ្តល់ការគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី
- រៀបចំ និងផ្តល់ផែនការបង្វែរជូនអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីពិនិត្យ និងសម្រេច
- ផ្តល់សេវាស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអនីតិជន
- ការកិច្ចចាំបាច់ផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

## ជំពូកទី ៥
## នគរបាលយុត្តិធម៌ និងការស៊ើបអង្កេត

### មាត្រា ១២.- សមត្ថកិច្ចនគរបាលយុត្តិធម៌ក្នុងការពិនិត្យបទឧក្រិដ្ឋ និងបទមជ្ឈិម

នគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម កំណត់អត្តសញ្ញាណ និងចាប់អនីតិជន ព្រមទាំងប្រមូលភស្តុតាង ។

នគរបាលយុត្តិធម៌ដែលចាប់ខ្លួន ឬមន្ត្រីនគរបាលយុត្តិធម៌ដែលឃាត់ខ្លួនអនីតិជន ត្រូវប្រគល់របាយការណ៍ និងកំណត់ហេតុលម្អិតស្តីពីការចាប់ ឬឃាត់ខ្លួន និងប្រគល់អនីតិជននោះទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន ។

### មាត្រា ១៣.- អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការពិនិត្យ និងដោះស្រាយបទលហុ

អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទលហុ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការអប់រំណែនាំ ព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ រួចហើយប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ជាបន្ទាន់ ។

ក្នុងករណីអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើស ហើយបទល្មើសនោះជាបទលហុ នគរបាលយុត្តិធម៌អាចធ្វើការសម្រុះសម្រួលរវាងភាគីពាក់ព័ន្ធដើម្បីបញ្ចប់វិវាទ ។

ករណីដែលមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ នគរបាលយុត្តិធម៌ត្រូវធ្វើរបាយការណ៍ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់ ។



ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នក តំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

**មាត្រា ១៤.- នីតិវិធីទាក់ទងនឹងអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ**

អនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីមន្ត្រីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

គ្រប់អំពើដែលជាបទល្មើសទាំងអស់ដែលប្រព្រឹត្តដោយអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ក្នុងករណីមានវិវាទទាក់ទងនឹងអាយុរបស់អនីតិជននៅពេលប្រព្រឹត្តបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងនេះទៅព្រះរាជអាជ្ញាជាបន្ទាន់ ។

## មាត្រា ១៥.- ការចាប់ខ្លួន

នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ តែក្នុងករណីដែលអនីតិជនប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ ។ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការចាប់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជននោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។ រាល់ការចាប់ខ្លួនអនីតិជនត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។

ការអនុវត្តការចាប់ខ្លួន នគរបាលយុត្តិធម៌ត្រូវចៀសវាងការធ្វើឲ្យអាម៉ាស់មុខនិងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន និងត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត ។

## មាត្រា ១៦.- ការឆែកឆេរលើខ្លួនបុគ្គល

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរលើខ្លួនបុគ្គលដែលជាអនីតិជនបាន ។ ការឆែកឆេរខ្លួនបុគ្គលត្រូវធ្វើឡើងដោយបុគ្គលដែលមានភេទដូចគ្នា និងមិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើស ពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយអនីតិជននោះឡើយ លើកលែងតែក្នុងករណីមិនអាចចៀសវាងបាន ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុនិងចុះនិទ្ទេសអំពីបញ្ហានេះ ។

## មាត្រា ១៧.- ការឃាត់ខ្លួនអនីតិជនប្រព្រឹត្តបទល្មើស

មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំបាន ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ជឿជាក់ថាអនីតិជនអាចរត់គេចខ្លួន ឬបំផ្លាញកស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារសុវត្ថិភាពអនីតិជននោះ ។ ប៉ុន្តែ អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការឃាត់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជន នោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។ រាល់ការឃាត់ខ្លួនអនីតិជន ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម ។ ការឃាត់ខ្លួននេះ សម្រាប់តែជាវិធានការចុងក្រោយប៉ុណ្ណោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ចប់ដំណើរការស៊ើបអង្កេតឲ្យបានលឿនបំផុតដែលអាចធ្វើទៅ

## មាត្រា ១៨.- ការជូនដំណឹងបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងជាបន្ទាន់ទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជនបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជននោះ ។ ក្នុងករណីមិនអាចផ្តល់ដំណឹងនេះជាបន្ទាន់ ត្រូវជូនដំណឹងដល់អ្នកតំណាងដែលច្បាប់បានកំណត់ក្នុងរយៈពេលយ៉ាងខ្លីបំផុតដែលអាចធ្វើ ទៅបាន អំពី ៖

- មូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន និងប្រភេទនៃបទល្មើស
- ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ
- សិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់នៅអង្គភាពនគរបាល ។

ក្នុងករណីមិនអាចទាក់ទងអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជនបាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រឹងប្រែងទាក់ទងអ្នកទំនុកបម្រុងដែលជ្រើសរើសដោយអនីតិជន ឬដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយមានការយល់ព្រមពីអនីតិជននោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងភ្លាមផងដែរទៅភ្នាក់ងារសង្គមកិច្ច បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីផ្តល់សេវាគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងភ្លាមទៅមេធាវីរបស់អនីតិជន ប្រសិនបើមាន ។ ក្នុងករណីដែលគ្មានការជ្រើសរើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានបញ្ជីឈ្មោះមេធាវីសម្រាប់ឲ្យអនីតិជនធ្វើការជ្រើសរើស ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែភាសាដោយមិនយកកម្រៃឲ្យអនីតិជន ក្នុងករណីដែលអនីតិជននោះពុំមានអ្នកបកប្រែភាសាផ្ទាល់ខ្លួន ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុដោយឡែកអំពីការជូនដំណឹង ឬការព្យាយាមជូនដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវីរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច និងស្វែងរកមេធាវីនិងអ្នកទំនុកបម្រុង ទោះបីជាការជូនដំណឹង ឬការព្យាយាមជូនដំណឹងនោះមិនបានទទួលលទ្ធផលក្តី។

## មាត្រា ១៩.- ការពិនិត្យសុខភាពផ្លូវកាយ ឬសុខភាពផ្លូវចិត្ត

ក្នុងករណីអនីតិជនមានរបួស ឬមានបញ្ហាសុខភាពហើយត្រូវការការព្យាបាល នគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជនទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតបំផុត ដើម្បីធ្វើការពិនិត្យព្យាបាល ។

រាល់ការចំណាយលើការពិនិត្យនិងព្យាបាលជាបន្ទុករបស់រដ្ឋ ក្នុងករណីដែលឪពុកម្តាយ ឬអ្នកអាណាព្យាបាលគ្មានលទ្ធភាព ។

កំណត់ហេតុ ឬរបាយការណ៍ពាក់ព័ន្ធនឹងសុខភាព ត្រូវបញ្ចូលទៅក្នុងសំណុំរឿង ។

**មាត្រា ២០.- កំណត់ហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន**

ច្បាប់ចម្លងនៃកំណត់ហេតុស្តីពីការចាប់ខ្លួននិងកំណត់ហេតុសរុបនៃការឃាត់ខ្លួនអនីតិជនត្រូវផ្តល់ឲ្យមេធាវីតាមការស្នើសុំ ។

នៅតាមអង្គភាពដែលមាននគរបាលយុត្តិធម៌នីមួយៗ ត្រូវមានបញ្ជីដោយឡែកស្តីពីការឃាត់ខ្លួនអនីតិជន ។

**មាត្រា ២១.- នីតិវិធីមុនការស្តាប់ចម្លើយ**

អនីតិជនត្រូវទទួលបានឱកាសសន្ទនា ឬទំនាក់ទំនងជាមួយអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច និងមេធាវីជាលក្ខណៈឯកជននិងជាសម្ងាត់ ប្រសិនបើមានការស្នើសុំ លើកលែងតែជនទាំងនេះមានការទាក់ទិនក្នុងរឿងជាមួយ ។ ការជួបសន្ទនាឬទាក់ទងគ្នាមានរយៈពេល ៣០ (សាមសិប) នាទី និងត្រូវធ្វើមុនពេលស្តាប់ចម្លើយ ប្រសិនបើអាចធ្វើទៅបាន ។

**មាត្រា ២២.- ការស្តាប់ចម្លើយ**

មុនពេលផ្តើមស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់អនីតិជនអំពីសិទ្ធិជាមូលដ្ឋានជាពិសេស គឺសិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី ។

ការស្តាប់ចម្លើយត្រូវប្រព្រឹត្តដោយមានវត្តមានរបស់មេធាវី ដោយប្រើប្រាស់នីតិវិធីកុមារមេត្រីមានលក្ខណៈជាឯកជននិងជាការសម្ងាត់ ។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចដែលមានសិទ្ធិ ហើយអាចផ្តល់ជំនួយដល់អនីតិជន មានសិទ្ធិចូលរួមក្នុងការស្តាប់ចម្លើយអនីតិជនបាន ។

មន្ត្រីនគរបាលយុត្តិធម៌អាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយ ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះ ត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។ ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់មិនអាចចូលរួមបាន ត្រូវអនុញ្ញាតឲ្យអ្នកទំនុកបម្រុងអនីតិជនចូលរួមជំនួស ប្រសិនបើមាន ។

ក្នុងករណីអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬមេធាវីរបស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ចក្នុងពេលស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដោយបញ្ជាក់ពីមូលហេតុនៃអវត្តមាននោះ ហើយបញ្ចូលក្នុងសំណុំរឿងរបស់អនីតិជន ។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានបាន មន្ត្រីនគរបាលយុត្តិធម៌ ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុញ្ញាតឲ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយ ។

អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមដៃលើកំណត់ហេតុនោះ ដោយត្រូវចុះនិទ្ទេស ។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចដែលមានវត្តមានត្រូវចុះហត្ថលេខា ឬផ្តិតស្រាមដៃលើកំណត់ហេតុ ។ ក្នុងករណីអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតស្រាមដៃលើកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស នៅក្នុងកំណត់ហេតុនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

## មាត្រា ២៣.- ការប្រព្រឹត្តមកលើអនីតិជនដែលត្រូវបានឃាត់ខ្លួន

មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកអនីតិជនដាក់បង្ហាញមុខជាដូរឡើយ ក្នុងករណីគ្មានការយល់ព្រមជាមុនពីអនីតិជន ដោយមានការពិគ្រោះយោបល់ជាមួយមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ។ ក្នុងករណីអនីតិជនយល់ព្រម ត្រូវមានកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងផ្តិតស្រាមដៃ ។

អនីតិជនដែលត្រូវឃាត់ខ្លួន ត្រូវដាក់ដាច់ដោយឡែកពីនីតិជន និងទៅតាមភេទ ។

អនីតិជនមិនត្រូវបានទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុតបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬទទួលរងអំពើអមនុស្សធម៌ណាមួយឡើយ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

## ជំពូកទី ៦
## ការចោទប្រកាន់

### មាត្រា ២៤.- សមត្ថកិច្ចរបស់អង្គការអយ្យការ

បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ ។ អយ្យការធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអនីតិជន ។

ការចោទប្រកាន់ករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជន ត្រូវឲ្យតំណាងអយ្យការដែលទទួលបានការចាត់តាំងពិសេសឲ្យកាន់រឿងក្តីអនីតិជន ទោះជាការចាត់តាំងនោះឲ្យធ្វើតែរឿងអនីតិជនដាច់ខាតឬមិនដាច់ខាតក្តី ។ តំណាងអយ្យការដែលនឹងត្រូវចាត់ឲ្យកាន់រឿងក្តីអនីតិជន ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងយុត្តិធម៌អនីតិជន ។

### មាត្រា ២៥.- ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន

ព្រះរាជអាជ្ញាត្រូវពិនិត្យសំណុំឯកសារ និងពាក្យប្តឹងដែលខ្លួនបានទទួល ដើម្បីផ្ទៀងផ្ទាត់អាយុរបស់អនីតិជន ។

ក្នុងករណីមានវិមតិសង្ស័យអំពីអាយុរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីស្វែងរកឲ្យឃើញអាយុពិតប្រាកដរបស់អនីតិជននោះ ។

ក្នុងករណីការស៊ើបអង្កេតបឋមនោះមិនអាចឈានដល់ការសន្និដ្ឋានអំពីអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងនេះទៅឲ្យចៅក្រមស៊ើបសួរ ។

### មាត្រា ២៦.- ការស្តាប់ចម្លើយ

ព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកចូលរួមស្តាប់ចម្លើយអំពីសិទ្ធិដែលមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ ដោយប្រើភាសានិងអាកប្បកិរិយាសមស្របទៅនឹងកម្រិតនៃការយល់ដឹងរបស់អនីតិជនមុនពេលធ្វើការស្តាប់ចម្លើយ ។ ក្នុងករណីដែលគ្មានការជ្រើសរើសព្រះរាជ-អាជ្ញាត្រូវចាត់តាំងមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះ ។

ការស្តាប់ចម្លើយអនីតិជនត្រូវធ្វើជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី ។ ការស្តាប់ចម្លើយនេះត្រូវមានវត្តមានមេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ។ ព្រះរាជអាជ្ញាអាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។

ក្នុងករណីអវត្តមានជនណាមួយខាងលើ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុ ។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជី ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមមេដៃ ។

ព្រះរាជអាជ្ញាត្រូវអនុញ្ញាតឲ្យមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយបាន ។

មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ចដែលមានវត្តមាន ត្រូវចុះហត្ថលេខាឬផ្តិតស្រាមមេដៃលើកំណត់ហេតុ ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខាឬផ្តិតស្រាមមេដៃលើកំណត់ហេតុ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

## មាត្រា ២៧.- ការតម្កល់រឿងទុកឥតចាត់ការចំពោះអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ

ក្នុងករណីអនីតិជនមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ព្រះរាជអាជ្ញាត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន ។

ក្រោយពីបានទទួលអនីតិជនពីព្រះរាជអាជ្ញាហើយ ប្រសិនបើមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត យល់ឃើញថាអនីតិជននោះចាំបាច់ត្រូវមានកិច្ចការពារនិងថែទាំ នោះមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បាន

កំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន ។

## មាត្រា ២៨.- អំណាចរបស់តំណាងអយ្យការក្នុងការបង្វែរ

ករណីអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។

ករណីព្រះរាជអាជ្ញាសម្រេចបង្វែរ បទប្បញ្ញត្តិនៃជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច ។

ប្រសិនបើការរៀបចំផែនការបង្វែរត្រូវការពេលវេលា ព្រះរាជអាជ្ញាត្រូវផ្អាកនីតិវិធីចោទប្រកាន់ និងបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ។

ព្រះរាជអាជ្ញាជូនដំណឹងដល់ជនរងគ្រោះឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីចោទប្រកាន់ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ព្រះរាជអាជ្ញា ត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ព្រះរាជអាជ្ញាអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ២៩.- ការឲ្យដំណឹងអំពីការចោទប្រកាន់

ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងភ្លាមដោយផ្ទាល់និងជាលាយលក្ខណ៍អក្សរទៅអនីតិជន ហើយប្រសិនបើសមស្រប ត្រូវឲ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ឬអ្នកទំនុកបម្រុងនិងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន ។

**មាត្រា ៣០.- ការបំបែកសំណុំរឿង**

ប្រសិនបើព្រះរាជអាជ្ញាពិនិត្យសំណុំរឿងឃើញថា អំពើប្រព្រឹត្តនោះមានសហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតជាអនីតិជនផង និងជានីតិជនផង ព្រះរាជអាជ្ញាអាចសម្រេចចេញដីកាបំបែកសំណុំរឿងរវាងអនីតិជន និងនីតិជនឲ្យដាច់ដោយឡែកពីគ្នា ។

## ជំពូកទី ៧
## ការស៊ើបសួរ

**មាត្រា ៣១.- សមត្ថកិច្ចនៃការស៊ើបសួរ**

ការស៊ើបសួរករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជន ជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរដែលមានជំនាញទាក់ទងនឹងអនីតិជន ។

**មាត្រា ៣២.- ការបើកការស៊ើបសួរ**

បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរភ្លាម ។

ជនត្រូវចោទជាអនីតិជន ត្រូវមានមេធាវីអមជានិច្ចក្នុងអំឡុងពេលស្ដាប់ចម្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ក្នុងករណីគ្មានការជ្រើសរើស ចៅក្រមស៊ើបសួរត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ។

**មាត្រា ៣៣.- ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ**

នៅពេលអនីតិជនបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណអនីតិជន ហើយប្រាប់អនីតិជនឲ្យបានដឹងអំពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើស ដែលបានកំណត់ដោយច្បាប់ ព្រមទាំងប្រាប់អំពីសិទ្ធិទាក់ទងនឹងដំណាក់កាលស៊ើបសួរដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

### មាត្រា ៣៤.- ការផ្តល់អាទិភាពចំពោះរឿងក្តីអនីតិជន

ចៅក្រមស៊ើបសួរត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ពិសេសរឿងក្តីដែលអនីតិជនកំពុងជាប់ឃុំបណ្តោះអាសន្ន ។

### មាត្រា ៣៥.- ការស្តាប់ចម្លើយអនីតិជន

ការស្តាប់ចម្លើយត្រូវធ្វើជាការសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី ។ ការស្តាប់ចម្លើយនេះត្រូវមានវត្តមានមេធាវីការពារ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច ។

ចៅក្រមស៊ើបសួរអាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។

ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុក្នុងករណីអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច ។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជីត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ ។

ចៅក្រមស៊ើបសួរត្រូវអនុញ្ញាតឲ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ប្រសិនបើមានការស្នើសុំ ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

### មាត្រា ៣៦.- ការលើកពេលស្តាប់ចម្លើយ

ក្នុងករណីអវត្តមានមេធាវី ចៅក្រមស៊ើបសួរត្រូវលើកពេលស្តាប់ចម្លើយ និងត្រូវកោះហៅមេធាវីដើម្បីចូលរួមក្នុងការស្តាប់ចម្លើយ លើកលែងតែក្នុងករណីបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបាត់បង់តម្រុយនៃភស្តុតាង ។ ប្រភេទនៃការបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

វត្តមាន ឬអវត្តមានរបស់មេធាវី មិនរារាំងចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការមិនឃុំខ្លួន ឬឃុំខ្លួនជាបណ្តោះអាសន្នឡើយ ។

## មាត្រា ៣៧.- ការព្យួរការសិក្សា និងការងារសម្រាប់អនីតិជន

ចៅក្រមស៊ើបសួរអាចបង្គាប់ទៅគ្រឹះស្ថានសិក្សា ឬនិយោជក មិនឲ្យព្យួរការសិក្សា ឬព្យួរការងាររបស់អនីតិជន ប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ ។

ក្នុងករណីអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬត្រូវអនុវត្តផែនការបង្វែរ គ្រឹះស្ថាន ឬនិយោជកអាចព្យួរការសិក្សា ឬព្យួរការងាររហូតដល់មានសេចក្តីសម្រេចរបស់តុលាការជាស្ថាពរ ។ ក្នុងករណីតុលាការសម្រេចសេចក្តីថាគ្មានទោសទេ នោះគ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឲ្យអនីតិជនចូលសិក្សា ឬធ្វើការជាធម្មតាឡើងវិញ ។

## មាត្រា ៣៨.- អំណាចរបស់ចៅក្រមស៊ើបសួរក្នុងការបង្វែរ

ចៅក្រមស៊ើបសួរត្រូវពិចារណាជាបឋមទៅលើការបង្វែរ ដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ចំពោះអនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈិម ។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។ ករណីចៅក្រមស៊ើបសួរសម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរដោយដីកាសម្រេច និងបង្គាប់ឲ្យដោះលែងអនីតិជនដែលត្រូវបានឃុំខ្លួន ប្រសិនបើអនីតិជននោះត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ទោះបីផែនការបង្វែរត្រូវការពេលវេលារៀបចំក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជន អំពីការសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ៣៩.- ការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនអនីតិជនបណ្តោះអាសន្ន ជាវិធានការចុងក្រោយ ។

បន្ថែមលើបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមុននឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែរ ប្រសិនបើមាន ។

អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នឡើយ ។ ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជននោះជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន ។

## មាត្រា ៤០.- ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់អនីតិជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាជំនួសឲ្យការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើអនីតិជនត្រូវចោទនោះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។ បន្ថែមលើបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ ៖

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប

ROYAUME DU CAMBODGE · LE SECRETARIAT DU PALAIS ROYAL

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- បង្គាប់មិនឲ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប ។

## មាត្រា ៤១.- ការដោះលែងឲ្យនៅក្រៅឃុំ

ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ដោយគំនិតផ្ដួចផ្ដើមរបស់ខ្លួន ។ ចៅក្រមស៊ើបសួរដែលមានបំណងដោះលែងអនីតិជនឲ្យនៅក្រៅឃុំ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលខ្លីបំផុត ។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ឬទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះ នៅក្នុងដីកាសម្រេចរបស់ខ្លួន ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ព្រះរាជអាជ្ញា អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងអនីតិជនអាចសុំឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ។ មេធាវីអាចសុំដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានដោយមានការយល់ព្រមពីអនីតិជន ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ ។

## មាត្រា ៤២.- ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ

មុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើរបាយការណ៍ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ ក្នុងករណីរបាយការណ៍

ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចផ្តល់របាយការណ៍បន្ថែមក្នុងរយៈពេលឆាប់បំផុតដែលអាចធ្វើទៅបាន ដោយមិនឲ្យលើសរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។

ដីកាដំណោះស្រាយលើកលែងចោទប្រកាន់មានអានុភាពនាំឲ្យដោះលែងអនីតិជនដែលជាប់ឃុំ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

### មាត្រា ៤៣.- ការប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍

មុននឹងសម្រេចប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ចំពោះដីកាលើកលែងចោទប្រកាន់ ដីកាសម្រេចឃុំខ្លួន ដីកាសម្រេចមិនឃុំខ្លួន ដីកាដោះលែងឲ្យនៅក្រៅឃុំ និងដីកាបង្វែររបស់ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាត្រូវពិចារណាជាចម្បងអំពីឧត្តមប្រយោជន៍របស់អនីតិជន ។

## ជំពូកទី ៨
## សមត្ថកិច្ចរបស់សាលាដំបូង

### មាត្រា ៤៤.- សមត្ថកិច្ចនៃការជំនុំជម្រះ

សាលាដំបូងដែលមានសមត្ថកិច្ចជំនាញទាក់ទងនឹងអនីតិជន ជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលមានជនជាប់ចោទជាអនីតិជន ។

សាលាដំបូងសម្រេចជាក្រុមសមូហភាពដោយមានចៅក្រម ៣ (បី) រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទងនឹងបទឧក្រិដ្ឋ និងបទមជ្ឈិម ។

សាលាដំបូងសម្រេចជាចៅក្រមទោលចំពោះបទលហុ ។

### មាត្រា ៤៥.- អាទិភាពលើរឿងក្តីអនីតិជន

តុលាការត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន ។

ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ តុលាការត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។ ករណីដែលរឿងក្តីត្រូវបានលើកពេលជំនុំជម្រះ តុលាការត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។

### មាត្រា ៤៦.- នីតិវិធីមុនពេលសវនាការ

មុនពេលសវនាការ តុលាការត្រូវពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច ។

ក្នុងករណីដែលរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់បានរៀបចំ ហើយតុលាការត្រូវការព័ត៌មានបន្ថែម តុលាការត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះ តាមតម្រូវការ ។

### មាត្រា ៤៧.- សវនាការជាអសាធារណៈ

ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ ។

មានតែបុគ្គលដែលមានសិទ្ធិ កាតព្វកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងសវនាការ ។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនត្រូវចូលរួមក្នុងសវនាការ លើកលែងតែមានសំណូមពរពីអនីតិជនផ្ទុយពីនេះ ឬតុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនោះមិនបម្រើឧត្តមប្រយោជន៍របស់អនីតិជន ។

### មាត្រា ៤៨.- សវនាការ

នៅពេលសវនាការ តុលាការត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រី ។

ក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឲ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ ។

**មាត្រា ៤៩.- ការឲ្យរួចផុតពីបទចោទ**

ក្នុងករណីតុលាការរកឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឲ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ហើយបង្គាប់ឲ្យដោះលែងអនីតិជនដែលជាប់ឃុំជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីតុលាការរកឃើញថាអនីតិជនខាងលើពិតជាបានប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណី ប្រសិនបើមានបណ្តឹងរដ្ឋប្បវេណី ។

ប្រសិនបើតុលាការរកឃើញថា អំពើដែលចោទប្រកាន់មកលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនមែនជាបទល្មើស ឬអនីតិជនជាប់ចោទគ្មានកំហុសទេ តុលាការត្រូវសម្រេចឲ្យរួចខ្លួនពីបទចោទ និងបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ ប្រសិនបើអនីតិជននោះមិនត្រូវបានជាប់ឃុំពីបទល្មើសផ្សេងទៀតទេ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ តុលាការត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

**មាត្រា ៥០.- ជំនួយរបស់មេធាវី**

ជំនួយរបស់មេធាវីត្រូវតែមានជាចាំបាច់នៅក្នុងសវនាការ ។ បើគ្មានការជ្រើសរើសដោយអនីតិជន មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃតាមគំនិតផ្តួចផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ សោហ៊ុយសម្រាប់ធ្វើការ ចម្លងសំណុំរឿងជាបន្ទុករបស់រដ្ឋ ។

តុលាការត្រូវផ្តល់ពេលវេលាសមស្រប និងលិខិតចម្លងសំណុំរឿង ទៅឲ្យមេធាវីសម្រាប់រៀបចំការការពារ ។ សោហ៊ុយសម្រាប់ធ្វើការចម្លងសំណុំរឿងជាបន្ទុករបស់មេធាវីដែលត្រូវបានជ្រើសរើសដោយអនីតិជន ។

**មាត្រា ៥១.- ការផ្តល់ព័ត៌មានអំពីសិទ្ធិដល់អនីតិជន**

នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បាន អំពីសិទ្ធិដូចខាងក្រោម ៖

- សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ
- សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី
- សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមម្យេ
- សិទ្ធិប្តឹងជិតចិត្តចៅក្រមជំនុំជម្រះ
- សិទ្ធិធ្វើសំណូមពរចុងក្រោយ និង
- សិទ្ធិប្តឹងឧទ្ធរណ៍ ។

**មាត្រា ៥២.- អំណាចរបស់តុលាការក្នុងការបង្វែរ**

នៅដំណាក់កាលនៃការជំនុំជម្រះលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ជាប់ចោទពីបទលហុ បទមជ្ឈិម តុលាការត្រូវពិចារណាជាបឋម ទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។

ក្នុងករណីលក្ខខណ្ឌអប្បបរមាត្រូវបានបំពេញ តុលាការត្រូវចេញសាលក្រមបង្អង់រឿងទុកសិនបន្ទាប់មកត្រូវ ៖

- ពិគ្រោះយោបល់ជាមួយអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងមេធាវី ភ្នាក់ងារសង្គមកិច្ច ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកពាក់ព័ន្ធផ្សេងទៀត
- រៀបចំផែនការបង្វែរ
- ឲ្យអនីតិជនចុះហត្ថលេខា ឬផ្តិតម្រាមដៃអនុវត្តផែនការបង្វែរ ។

ក្នុងករណីតុលាការសម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូកទី ១០(ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ តុលាការអាចចេញសាលក្រមសម្រេចអំពីសំណងរដ្ឋប្បវេណី ក្នុងករណីមានការប្តឹងសុំ ។

ប្រសិនបើអនីតិជនកំពុងជាប់ឃុំ តុលាការត្រូវបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ តុលាការត្រូវបញ្ជូនអនីតិជននោះ ទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនអនុវត្តបានជោគជ័យនូវផែនការបង្វែរ ដោយមានរបាយការណ៍បញ្ជាក់រួមគ្នារបស់ភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ តុលាការត្រូវចេញសាលក្រមសម្រេចឲ្យអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ ។

ក្នុងករណីការអនុវត្តផែនការបង្វែរទទួលបរាជ័យ តុលាការអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជនអ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ៥៣.- ចម្លើយសារភាពនៅពេលសវនាការ

តុលាការត្រូវពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ និងយល់បានអំពីផលវិបាកនៃការសារភាពនេះ ។ ចម្លើយសារភាពដែលបានមកពីការគំរាមកំហែងការបង្ខិតបង្ខំ ឬការមិនយល់ដឹងអំពីផលវិបាកនៃការសារភាពមិនត្រូវចាត់ទុកជាភស្តុតាង នៃពិរុទ្ធភាពឡើយ ។

ការសារភាពទទួលយកផែនការបង្វែរមិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដដែល សម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់នោះឡើយ ។

ក្នុងពេលសវនាការតុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស ។

## មាត្រា ៥៤.- ការប្រកាសសាលក្រម

សាលក្រមត្រូវប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ ។

ជាគោលការណ៍ សាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្តី ។

សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឲ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ។

## ជំពូកទី ៩
## សមត្ថកិច្ចរបស់តុលាការជាន់ខ្ពស់

### មាត្រា ៥៥.- សមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះ

ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ និងតុលាការកំពូលត្រូវមានសមាសភាពជាចៅក្រមជំនាញទាក់ទងនឹងអនីតិជនយ៉ាងតិច ១ (មួយ) រូប ។

### មាត្រា ៥៦.- ការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ និងតុលាការកំពូល

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃសាលាដំបូងត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅសាលាឧទ្ធរណ៍ ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជម្នះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន ។

ក្នុងករណីមានបណ្តឹងសាទុក្ខ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅតុលាការកំពូល ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្តឹងសាទុក្ខ លើកលែងតែមានកាលៈទេសៈមិនអាចជម្នះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន ។

### មាត្រា ៥៧.- អាទិភាពនៃរឿងក្តីអនីតិជន

សាលាឧទ្ធរណ៍ និងតុលាការកំពូល ត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការ ជំនុំជម្រះជាអាទិភាព ពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំ ។ ចំពោះរឿងក្តីដែលអនីតិជនជាប់ឃុំ ត្រូវលើកយកមកជំនុំជម្រះក្នុងអំឡុងពេល ៣ (បី) ខែ យ៉ាងយូរគិតពីថ្ងៃទទួលសំណុំរឿង លើកលែងតែមានមូលហេតុសត្យានុម័តដែលមិនអាចជម្នះបាន ។

ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ សាលាឧទ្ធរណ៍ឬតុលាការកំពូលត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។ ក្នុងករណីរឿងក្តីត្រូវបានលើកពេលជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។

### មាត្រា ៥៨.- អំណាចរបស់សាលាឧទ្ធរណ៍ក្នុងការបង្វែរ

បទប្បញ្ញត្តិនៃមាត្រា ៥២ (អំណាចរបស់តុលាការក្នុងការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះអំណាចក្នុងការបង្វែររបស់សាលាឧទ្ធរណ៍ ។

**មាត្រា ៥៩.- ការពន្លាតវិធានដល់តុលាការជាន់ខ្ពស់**

វិធានដែលត្រូវអនុវត្តចំពោះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍ និងតុលាការកំពូល លើកលែងតែវិធាននោះមានភាពផ្ទុយពីលក្ខណៈនៃវិធានដែលអនុវត្តនៅតុលាការជាន់ខ្ពស់ ។

## ជំពូកទី ១០
## ការបង្វែរ

**មាត្រា ៦០.- ការបង្វែរ**

ការបង្វែរជាវិធានដែលអាចប្រើប្រាស់ក្នុងករណីអនីតិជនបានសារភាពថា បានប្រព្រឹត្តបទល្មើស ហើយដែលអាចជឿជាក់បានថាបានប្រព្រឹត្តបទល្មើសមែន ចេញពីដំណាក់កាលនីមួយៗ នៃនីតិវិធីតុលាការ ។

**មាត្រា ៦១.- អាជ្ញាធរទទួលបន្ទុកបង្វែរ**

អាជ្ញាធរទទួលបន្ទុកបង្វែររួមមាន តំណាងអង្គការអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ ។

**មាត្រា ៦២.- គោលបំណងនៃការបង្វែរ**

ការបង្វែរអនីតិជនមានគោលបំណងដូចខាងក្រោម៖

- លើកទឹកចិត្តអនីតិជនឲ្យទទួលស្គាល់កំហុស និងការខូចខាតដែលខ្លួនបានបង្កឡើង
- ជំរុញឲ្យមានការសះជារវាងជនរងគ្រោះជាមួយនឹងអនីតិជន
- លើកទឹកចិត្តឲ្យមានការជួសជុលការខូចខាត ឬសំណងជំងឺចិត្តដល់ជនរងគ្រោះ
- អប់រំ និងកែប្រែអាកប្បកិរិយារបស់អនីតិជន
- ឆ្លើយតបនឹងសេចក្តីត្រូវការផ្ទាល់របស់អនីតិជន ដើម្បីធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ឬសហគមន៍ ឬសង្គមវិញ
- ចៀសវាងការមានស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍ និងបញ្ចៀសការទទួលបាននូវបទពិសោធអាក្រក់នៃការប្រព្រឹត្តបទល្មើសពីជនដទៃក្នុងពេលអនុវត្តទោស និងចៀសវាងការប្រព្រឹត្តបទល្មើសសាជាថ្មី
- បង្ការការរើសអើងលើអនីតិជន និងចៀសវាងមានប្រវត្តិថាជាប់ទោសក្នុងបញ្ជីថ្កោលទោស ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

### មាត្រា ៦៣.- លក្ខខណ្ឌអប្បបរមានៃការបង្វែរ

ការបង្វែរត្រូវមានលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

ក- មានកស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន ។

ខ- អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ ។

គ- បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬបទមជ្ឈិម ។

ឃ- អនីតិជនយល់ព្រមឲ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានបង្វែរ ។

### មាត្រា ៦៤.- លក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ

ក្នុងករណីរឿងក្តីបំពេញទៅតាមលក្ខខណ្ឌអប្បបរមានៃការបង្វែរ ដូចមានចែងនៅក្នុងមាត្រា ៦៣ (លក្ខខណ្ឌអប្បបរមានៃការបង្វែរ) នៃច្បាប់នេះ អាជ្ញាធរទទួលបន្ទុកបង្វែរ មុននឹងសម្រេចបង្វែរ ឬមិនបង្វែរ ត្រូវពិចារណាលើកត្តាដូចខាងក្រោម ៖

ក- កាលៈទេសៈនៃបទល្មើស ។

ខ- ស្ថានភាពនៃបទល្មើស ។

គ- បុគ្គលិកលក្ខណៈរបស់អនីតិជនដូចជា អាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត ។

ឃ- ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន ។

ង- ព្យសនកម្មរបស់ជនរងគ្រោះ ។

ច- សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គម ។

### មាត្រា ៦៥.- វិធានការបង្វែរ

ក្នុងករណីដែលត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចសម្រេចជ្រើសរើសយកវិធានមួយ ឬច្រើនដូចខាងក្រោម សម្រាប់ឲ្យអនីតិជនបំពេញជាកាតព្វកិច្ច ៖

- ចំណុចមួយ ឬច្រើនដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ
- ទៅសាលារៀនឲ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ (ប្រាំមួយ) ខែ
- ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ (ប្រាំមួយ) ខែ
- តម្រូវឲ្យចូលរួមក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈក្នុងចិរវេលាមិនលើសពី ៦ (ប្រាំមួយ)ខែ

- ធ្វើការងារសហគមន៍ដោយមិនលើសពី ១០០ (មួយរយ) ម៉ោង ។ ការងារសហគមន៍នេះ សម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឡើងទៅ ហើយមាន លក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ
- ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍ សម្រាប់ជួយអនីតិជន មិនឲ្យប្រព្រឹត្តបទល្មើសសាជាថ្មី
- ឲ្យស្នាក់នៅទីកន្លែងណាមួយដោយកំណត់ពេលវេលាជាក់លាក់
- ជួសជុលសំណងការខូចខាតទៅជនរងគ្រោះ
- វិធានការសមស្របផ្សេងទៀតដែលបំពេញនូវគោលបំណងនៃការបង្វែរ ។

រាល់វិធានការបង្វែរដែលទាក់ទងនឹងការងារ ត្រូវអនុលោមតាមច្បាប់ស្តីពីការងារ និងអនុសញ្ញា អន្តរជាតិស្តីពីការងារដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

## មាត្រា ៦៦._ ការរៀបចំបង្កើតផែនការបង្វែរ

ក្រោយពីបានទទួលដីកាសម្រេចបង្វែរពីអាជ្ញាធរទទួលបន្ទុកបង្វែរ ភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំ បង្កើតផែនការបង្វែរ ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃ ទទួលដំណឹងអំពីដីកាសម្រេចបង្វែរ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន ។

ក្នុងការបង្កើតផែនការបង្វែរជាឯកត្តបុគ្គលសម្រាប់អនីតិជនណាមួយ ភ្នាក់ងារសង្គមកិច្ចត្រូវ ពិចារណាទៅលើកត្តាដូចខាងក្រោម ៖

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនដទៃទៀតដែលទទួល រងផលប៉ះពាល់នៃអំពើល្មើស អំពីភាពសមស្របនៃផែនការបង្វែរដែលត្រូវបានស្នើឡើង
- សាវតារ វប្បធម៌ សាសនា និងភាសារបស់អនីតិជន
- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន
- សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសចំពោះស្ថានភាពរបស់អនីតិជន ចរិត នៃបទល្មើស និងផលប្រយោជន៍សង្គម និង
- អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជន ។

ផែនការបង្វែរសម្រាប់អនីតិជនត្រូវ ៖

- ផ្តល់នូវអត្ថប្រយោជន៍សម្រាប់អនីតិជន
- ធ្វើឲ្យអនីតិជនយល់ពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះនៃបទល្មើស និងជនដទៃទៀត
- កែតម្រូវនូវកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអាចរួមបញ្ចូលទាំងសំណង ការខូចខាត

- អនុវត្តនៅទីកន្លែងដែលអនីតិជនអាចអនុវត្តបាន
- ចៀសវាងការធ្វើអាជីវកម្មកេងប្រវ័ញ្ច ឬបណ្តាលឲ្យអន្តរាយ ឬធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ឬផ្លូវកាយរបស់អនីតិជន
- មិនប៉ះពាល់ជាអវិជ្ជមានដល់ការសិក្សារបស់អនីតិជន បើអនីតិជនកំពុងសិក្សា និង
- មិនមានការពាក់ព័ន្ធនឹងការដកហូតសេរីភាព នៅក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ ។

## មាត្រា ៦៧.- និទ្ទេសដែលត្រូវចុះនៅក្នុងផែនការបង្វែរ

ផែនការបង្វែរត្រូវមាននិទ្ទេសដូចខាងក្រោម ៖

- វិធានការបង្វែរណាមួយដូចមានចែងក្នុងមាត្រា ៦៥ (វិធានការបង្វែរ) នៃច្បាប់នេះ និងរយៈពេលនៃការអនុវត្តវិធានការបង្វែរ
- បញ្ជាក់លម្អិតអំពីសេវា និងជំនួយដែលត្រូវផ្តល់ឲ្យអនីតិជន
- បញ្ជាក់ឲ្យច្បាស់ពីបុគ្គល ឬអង្គការដែលផ្តល់សេវា និងជំនួយទាំងនោះ
- បញ្ជាក់ពីការទទួលខុសត្រូវរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ជាក់ពីគោលបំណងផ្ទាល់ខ្លួនរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ចូលកម្មវិធីផ្សេងទៀតទាក់ទងនឹងការអប់រំ ការបម្រើការងារ ការកម្សាន្ត និងសុខុមាលភាពរបស់អនីតិជនទៅតាមស្ថានភាពដែលពាក់ព័ន្ធ
- បញ្ជាក់ពីអាជ្ញាធរ ឬជនសមស្របដែលទទួលបន្ទុកអនុវត្តផែនការបង្វែរ ។ អាជ្ញាធរ ឬជនសមស្របទាំងនេះអាចជានគរបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ្រូបង្រៀន ឬសមាជិកសមស្របណាមួយនៃសហគមន៍
- បញ្ជាក់ពីភ្នាក់ងារសង្គមកិច្ចដែលទទួលបន្ទុកត្រួតពិនិត្យតាមដាន និងអនុវត្តផែនការបង្វែរ
- បញ្ជាក់អំពីការយល់ព្រមរបស់អនីតិជនចំពោះផែនការបង្វែរ ។

ផែនការបង្វែរត្រូវចុះ ៖

- អត្តសញ្ញាណ និងហត្ថលេខារបស់ភ្នាក់ងារសង្គមកិច្ច
- អត្តសញ្ញាណ និងស្នាមម្រាមដៃរបស់អនីតិជន
- អត្តសញ្ញាណ ហត្ថលេខា ឬស្នាមម្រាមដៃរបស់បុគ្គលដែលពាក់ព័ន្ធ ។

ច្បាប់ចម្លងនៃផែនការបង្វែរត្រូវរក្សាទុកជាការសម្ងាត់នៅការិយាល័យរបស់ភ្នាក់ងារសង្គមកិច្ច ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## មាត្រា ៦៨.- ការសម្រេចអំពីផែនការបង្វែរដោយអាជ្ញាធរទទួលបន្ទុកបង្វែរ

ភ្នាក់ងារសង្គមកិច្ច ត្រូវបញ្ជូនផែនការបង្វែរទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីពិនិត្យ និងសម្រេច ។

ករណីអាជ្ញាធរទទួលបន្ទុកបង្វែរយល់ស្របចំពោះផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវចេញដីកាសម្រេចឲ្យអនុវត្តផែនការបង្វែរ ។

ករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនយល់ស្រប ចំពោះផែនការបង្វែរដែលរៀបចំដោយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំឡើងវិញនូវផែនការបង្វែរថ្មី ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាបង្គាប់ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន ។

## មាត្រា ៦៩.- ការអនុវត្តផែនការបង្វែរ

ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវជានាប់រងអនុវត្តសេចក្តីសម្រេច និងផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ ។

បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាន នៅក្នុងការអនុវត្តផែនការខាងលើទៅភ្នាក់ងារសង្គមកិច្ច ។ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះរួមទាំងយោបល់របស់ខ្លួន ទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ។

## មាត្រា ៧០.- ការកែប្រែវិធានការបង្វែរ

ក្នុងអំឡុងពេលអនុវត្តផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចកែប្រែវិធានការបង្វែរបានតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ចស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីជាប្រយោជន៍របស់អនីតិជន ។

អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ច ។ ក្នុងករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនបានសម្រេចក្នុងថិរវេលានេះ ត្រូវចាត់ទុកថាយល់ស្របតាមការស្នើសុំ ។

ការកែប្រែផែនការបង្វែរ មិនចាត់ទុកថាជាការបរាជ័យក្នុងការអនុវត្តផែនការបង្វែរឡើយ ។

## មាត្រា ៧១.- បរាជ័យក្នុងការអនុវត្តវិធានការបង្វែរ

បរាជ័យក្នុងការអនុវត្តវិធានការបង្វែរ សំដៅដល់ករណីដែលអនីតិជនមិនបានគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែ ។

ភ្នាក់ងារសង្គមកិច្ចត្រូវផ្តល់របាយការណ៍ស្តីពី លទ្ធផលនៃការមិនគោរពកាតព្វកិច្ចដែលបានកំណត់នៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែ រួមទាំងយោបល់ជូនទៅអាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីសម្រេច ដោយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ។

ក្រោយពិនិត្យរបាយការណ៍ខាងលើ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ និងមេធាវីរបស់អនីតិជន ប្រសិនបើមាន ឲ្យចូលមកបង្ហាញខ្លួនក្នុងចិរវេលា មិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ ។

អាជ្ញាធរទទួលបន្ទុកបង្វែរ ត្រូវសាកសួរពីមូលហេតុដែលអនីតិជននោះមិនគោរពតាមវិធានការបង្វែរ ។

ក្រោយពីបានពិចារណាអំពីទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរអាចចេញដីកាបង្វែរថ្មី ឬបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

បទប្បញ្ញត្តិនៃមាត្រា ៦៦ (ការរៀបចំបង្កើតផែនការបង្វែរ) ដល់ មាត្រា ៧០ (ការកែប្រែវិធានការបង្វែរ)ខាងលើនេះ ត្រូវយកមកអនុវត្តក្នុងករណីដែលអាជ្ញាធរទទួលបន្ទុកបង្វែរចេញដីកាបង្វែរថ្មី ។

ក្នុងករណីអនីតិជនមិនបង្ហាញខ្លួនតាមការកោះហៅដោយគ្មានមូលហេតុសមស្រប អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវបន្តចាត់ការបន្តតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ១១
## ការដោះលែងដោយមានលក្ខខណ្ឌ

### មាត្រា ៧២.- ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវផ្តល់ឲ្យដល់ទណ្ឌិតជាអនីតិជនដែលទទួលរងទោសក្នុងមណ្ឌលយុវនីតិសម្បទា ៖

- ចំនួនមួយភាគបីនៃទោស ប្រសិនបើទោសតិចជាង ឬស្មើ ១ (មួយ) ឆ្នាំ
- ចំនួនពាក់កណ្តាលនៃទោស ក្នុងករណីផ្សេងទៀត ។

### មាត្រា ៧៣.- បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងដោយមានលក្ខខណ្ឌ

បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌ រួមមាន ៖

- ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់ជននោះ
- អ្នកតំណាងដែលច្បាប់បានកំណត់
- ប្រធានមណ្ឌលយុវនីតិសម្បទា

- ភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជននោះ
- បេសកកម្មការទូត ឬកុងស៊ុលបរទេស ក្នុងករណីអនីតិជនជាជនបរទេស ។

## ជំពូកទី ១២
## ការផ្តល់ និងការមាននីតិសម្បទាឡើងវិញ

### មាត្រា ៧៤.- លក្ខខណ្ឌលើរយៈពេលទាក់ទងនឹងពាក្យសុំឲ្យមានការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

ពាក្យសុំឲ្យមាននីតិសម្បទាឡើងវិញអាចនឹងដាក់ជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែផុតរយៈពេលដូចតទៅ ៖

- ២ (ពីរ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៦ (ប្រាំមួយ) ខែ ចំពោះបទមជ្ឈិម
- ១ (មួយ) ខែ ចំពោះបទលហុ ។

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ។

ពាក្យសុំអាចត្រូវធ្វើឡើងដោយ ៖

- ទណ្ឌិតជានីតិជនដែលបានប្រព្រឹត្តបទល្មើសនៅពេលខ្លួនជាអនីតិជន
- អ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីទណ្ឌិតជាអនីតិជន ។

### មាត្រា ៧៥.- ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់

នីតិសម្បទាត្រូវមានឡើងវិញដោយពេញលក្ខណៈច្បាប់នៅពេលផុតរយៈពេល ៖

- ៣ (បី)ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ១ (មួយ)ឆ្នាំ ចំពោះបទមជ្ឈិម
- ៣ (បី)ខែ ចំពោះបទលហុ។

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ។

## ជំពូកទី ១៣
## ការបង្កើត និងសមត្ថកិច្ចគ្រប់គ្រងមណ្ឌលយុវនីតិសម្បទា

### មាត្រា ៧៦.‒ ការបង្កើតមណ្ឌលយុវនីតិសម្បទា

ត្រូវបង្កើតឲ្យមានមណ្ឌលយុវនីតិសម្បទានៅតាមរាជធានី ខេត្ត សម្រាប់គ្រប់គ្រងអនីតិជន ។ មណ្ឌលនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ៧៧.‒ ការបែងចែកការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

ការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវបែងចែកជា ៣ (បី) ផ្នែកដាច់ដោយឡែកពីគ្នា ៖

- ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន
- ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា
- ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម ។

បែបបទនៃការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាដែលត្រូវជាប់ឃុំ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

### មាត្រា ៧៨.‒ បញ្ជីឈ្មោះអនីតិជន

គ្រប់មណ្ឌលយុវនីតិសម្បទា ត្រូវមានបញ្ជី និងនីតិវិធីដោយឡែកសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជន ព្រមទាំងបំពេញព័ត៌មានពាក់ព័ន្ធទាំងអស់ និងរក្សាឲ្យមានសុវត្ថិភាព ។

បញ្ជី និងនីតិវិធីដោយឡែកនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## ជំពូកទី ១៤
## វិធានការទាក់ទងនឹងការឃុំខ្លួនអនីតិជន

### មាត្រា ៧៩.‒ គោលបំណងនៃការឃុំខ្លួន

ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងស្តារនីតិសម្បទា ជាអាទិ៍ ការបណ្តុះបណ្តាលការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឲ្យក្លាយទៅជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ ។

មន្ត្រីមណ្ឌលយុវនីតិសម្បទាដែលទទួលបន្ទុកគ្រប់គ្រងអនីតិជន ត្រូវទទួលការបណ្ដុះបណ្ដាលអំពីចិត្តសាស្ត្រ សុខុមាលភាព បទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងកុមារ និងវិធានការសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

## មាត្រា ៨០.- សិទ្ធិជាមូលដ្ឋានរបស់អនីតិជនដែលជាប់ឃុំ

អនីតិជនដែលជាប់ឃុំទាំងអស់ត្រូវទទួលបានសិទ្ធិជាមូលដ្ឋានដូចតទៅ ៖

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្ម រួមមានការដាក់ឲ្យនៅឯកា ការដាក់កំហិត ឬបដិសេធមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ
- សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្ដីថ្លៃថ្នូររបស់អនីតិជន
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច
- សិទ្ធិផ្ដល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ការដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជំងឺ ឬរបួស និងផ្ដល់ដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការអនុញ្ញាតឲ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ ឬមិត្តភក្ដិ
- សិទ្ធិទទួលបានយន្តការបណ្ដឹងប្រកបដោយប្រសិទ្ធភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន
- សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន ។

## មាត្រា ៨១.- សេវាសម្រាប់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកមណ្ឌលយុវនីតិសម្បទាទាំងអស់ ត្រូវផ្ដល់សេវាដល់អនីតិជនដែលកំពុងជាប់ឃុំដូចខាងក្រោមនេះ ៖

- ការពារ ថែទាំ និងផ្ដល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន
- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល
- សិក្សាអប់រំ បណ្ដុះបណ្ដាលវិជ្ជាជីវៈ សិល្បៈ កីឡា កម្សាន្ត និងសម្រាកពីការងារ

- សុខភាពផ្លូវកាយនិងផ្លូវចិត្តសមស្រប
- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យ ។ ត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងអនីតិជនជាប់ឃុំនៃព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត
- សេវាផ្សេងទៀតដែលលើកស្ទួយសុខភាពនិងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឲ្យមានគំនិតទទួលខុសត្រូវ លើកទឹកចិត្តឲ្យមានអាកប្បកិរិយា និងជំនាញដែលនឹងជួយអនីតិជនក្នុងការអភិវឌ្ឍសក្តានុពលរបស់ខ្លួនក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និងជួយឲ្យពួកគេវិលត្រឡប់មកក្នុងសង្គមវិញបន្ទាប់ពីបានដោះលែង ។

## មាត្រា ៨២.- ការរក្សាអនីតិជន

ត្រូវរក្សាអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទាដូចខាងក្រោមនេះ ៖

- អនីតិជនត្រូវដាក់ដោយឡែកពីនីតិជន
- នៅក្នុងអគារដាច់ដោយឡែកទៅតាមភេទផ្សេងគ្នា តាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន ។ អនីតិជនភេទស្រីត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា
- នៅក្នុងអគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែកសម្រាប់អនីតិជនដែលមានជំងឺឆ្លង ។

ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងពេលបាន និងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងមណ្ឌលយុវនីតិសម្បទាបន្តរហូតដល់អាយុក្រោម ២៤ (ម្ភៃបួន) ឆ្នាំ។ នៅពេលទណ្ឌិតឈានចូលអាយុគ្រប់ ២៤ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជន ។

បែបបទនិងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## មាត្រា ៨៣.- ចំណាត់ថ្នាក់សន្តិសុខនៅក្នុងមណ្ឌលយុវនីតិសម្បទា

ចំណាត់ថ្នាក់សន្តិសុខសម្រាប់អនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវស្ថិតក្នុងចំណាត់ថ្នាក់ទាបបំផុត និងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

**មាត្រា ៨៤.- ភ្នាក់ងារក្នុងមណ្ឌលឃុំឃាំងអនីតិជន**

ភ្នាក់ងារទាំងអស់ដែលធ្វើការជាមួយអនីតិជននៅក្នុងមណ្ឌលឃុំឃាំងអនីតិជន ជាអាទិ៍ មន្ត្រីមណ្ឌលឃុំឃាំងអនីតិជន ភ្នាក់ងារសង្គមកិច្ច អ្នកជំនាញផ្នែកអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អ្នកពិគ្រោះយោបល់ និងបំណិនជីវិត និងអ្នកចិត្តសាស្ត្រ ឬគ្រូពេទ្យព្យាបាលជំងឺផ្លូវចិត្ត ត្រូវតែទទួលបាននូវការបណ្តុះបណ្តាលត្រឹមត្រូវអំពីចិត្តសាស្ត្រកុមារ សុខុមាលភាពកុមារ និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិកុមារ និងការប្រព្រឹត្តមកលើអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

មន្ត្រី ឬបុគ្គលិកមណ្ឌលឃុំឃាំងអនីតិជន មិនត្រូវប្រើ ឬបញ្ជាជនដែលកំពុងជាប់ឃុំឲ្យដាក់វិន័យទៅលើអនីតិជន ឬធ្វើកិច្ចការជំនួសខ្លួនឡើយ ។

**មាត្រា ៨៥.- ការធ្វើអធិការកិច្ចមណ្ឌលឃុំឃាំងអនីតិជន**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចជាប្រចាំលើមណ្ឌលឃុំឃាំងអនីតិជន ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងធានាថាលក្ខខណ្ឌនៃការប្រព្រឹត្ត និងការឃុំខ្លួនត្រូវអនុវត្តដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមាន ។

យន្តការបង្ការថ្នាក់ជាតិ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់មានសិទ្ធិធ្វើទស្សនកិច្ចមណ្ឌលឃុំឃាំងអនីតិជនបានគ្រប់ពេលវេលា ។

## ជំពូកទី ១៥
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៦.- បទប្បញ្ញត្តិទាក់ទងនឹងចៅក្រម**

ចៅក្រមអយ្យការ និងចៅក្រមដែលត្រូវបានចាត់ឲ្យទទួលបន្ទុកលើរឿងក្តីអនីតិជនតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវចាត់ការបន្តរហូតដល់ពេលមានចៅក្រមជំនាញទាក់ទងនឹងអនីតិជន ។

**មាត្រា ៨៧.- នគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន**

នគរបាលយុត្តិធម៌ដែលកំពុងចាត់ការលើរឿងក្តីអនីតិជនតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវចាត់ការបន្តរហូតដល់ពេលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន ។

**មាត្រា ៨៨.- មណ្ឌលយុវនីតិសម្បទា**

ក្នុងករណីមិនទាន់មានមណ្ឌលយុវនីតិសម្បទា វិធានការទាំងឡាយដែលកំពុងអនុវត្តទៅលើអនីតិជន ត្រូវបន្តអនុវត្តរហូតដល់មានមណ្ឌលយុវនីតិសម្បទា ។

បែបបទ និងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលអនីតិជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## ជំពូកទី ១៦
## អវសានប្បញ្ញត្តិ

**មាត្រា ៨៩.- ការអនុវត្តច្បាប់នេះ**

ក្រោយពីចូលជាធរមាននៅទូទាំងប្រទេស ច្បាប់នេះត្រូវផ្សព្វផ្សាយរយៈពេល ៦ (ប្រាំមួយ) ខែ ទើបអនុវត្ត ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៦
**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាសប់បន្ទាប់**
**ប្រមុខរដ្ឋស្ដីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

នស/រកម/០៧១៦/០១០

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
**ហត្ថលេខា**
**វង សូត**

លេខៈ ៧៦៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី ៧
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** បញ្ចប់មុខតំណែងឯកឧត្តម **តូច ឡាវីណូវ៉ង់** ពីជំនួយការសម្តេច **នរោត្តម សិរីវុឌ្ឍ** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២ :** តែងតាំងនិងផ្តល់ឋានៈឯកឧត្តម **យិន វីរៈ** ជាជំនួយការសម្តេច **នរោត្តម សិរីវុឌ្ឍ** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា៣ :** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ចរល.១៦០៧.៧២៤

លេខៈ ៧២៩ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧១៨

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ  នរោត្តម  សីហមុនី
## សមានភូមិជាតិសាសនា  រក្ខតខត្តិយា  ខេមររដ្ឋរាស្ត្រ  ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា  សមូហោភាស  កម្ពុជឯករាជរដ្ឋបូរណសន្តិ  សុភមង្គលា  សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ  ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ  ជស/រកម/០៤៩៨/០៦  ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨  ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ  នស/រកម/០១០៧/០០៥  ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧  ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ  នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី  ២១  ខែ  មិថុនា  ឆ្នាំ  ២០១៦  ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី ៧
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងនិងផ្តល់ឋានៈទីប្រឹក្សា និងជំនួយការឯកឧត្តម **អ៊ឹម  ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ផន  ស៊ីន**  ជាទីប្រឹក្សា  មានឋានៈស្មើ **រដ្ឋលេខាធិការ**
២- ឯកឧត្តម **ឈី  សំណាង**  ជាទីប្រឹក្សា  មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
៣- ឯកឧត្តម **ជិន  សុភាព**  ជាជំនួយការ  មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២ :** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៧  ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម  និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ចរស.១៦០៧.៧២៥

លេខ: ៧២៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២០  ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី ៧
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងនិងផ្តល់ឋានៈទីប្រឹក្សា និងជំនួយការឯកឧត្តម **សំ ព្រហ្មនា** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **សំ ព្រហ្មនី** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ**
២- ឯកឧត្តម **ខោល ទោហិត្ថិ៍** ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
៣- ឯកឧត្តម **ណើរ ណារិទ្ធ** ជាជំនួយការ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២ :** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ចារល. ១៦០៧.៧៤៦

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខៈ ៧៣០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ.ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧២០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី ៧
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងនិងផ្តល់ឋានៈទីប្រឹក្សា និងជំនួយការសម្តេចរាជបុត្រីព្រះរៀម **នរោត្តម បុប្ផាទេវី** សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម :

១- លោកជំទាវ **ទេព សននណារីម** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ**
២- លោកជំទាវ **ង៉ាម នងរដ្ឋា** ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
៣- អ្នកម្នាង **ស៊ីសុវត្ថិ ផល្លា** ជាជំនួយការ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២ :** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

[illegible]. ១៦០៧. ៧២៧

លេខ: ៧៣១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧២១

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ស្ដីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី ៧
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** បញ្ចប់មុខតំណែងឯកឧត្តម **ម៉េង គីមលី** ពីទីប្រឹក្សាឯកឧត្តម **ពិត តាំងសាន** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** តែងតាំងនិងផ្ដល់ឋានៈលោកជំទាវ **ពិត សុភក្ដិ** ជាទីប្រឹក្សាឯកឧត្តម **ពិត តាំងសាន** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា៣ :** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

ពរល.១៦០៧.៧២៤

លេខៈ ៧២៧ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៤២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** ១- តែងតាំងឯកឧត្តម **ខៀវ បូរិន** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន

២- តែងតាំងនិងផ្តល់ឋានៈឯកឧត្តម **ម៉េង សាវុធ** ជាជំនួយការអមក្រសួងបរិស្ថាន មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៣៩៧.១៦០៧.៧៣១

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខ ៧៦២ . ស.ណ
**សំណៅដែលមានអត្ថដូចការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧២៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងនិងផ្តល់ឋានៈឯកឧត្តម **គោរគ សំអុន** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ចរស. ១៦០៧.៧៣២

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខ: ៧១៦ ស.ណ
សំណៅចំលងមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៤៨?

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦ )

## ត្រាស់បង្គាប់

**តែងតាំង :**

១- លោក **គួច ហ៉ត**

២- លោក **វណ្ណា សុខហេង**

ជា

**ឧកញ៉ា**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ពរ.១៦០៧.៧៣៣?

លេខ: ៧១៥?.ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧? ខែ កក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៤៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** ប្តូរ និងដំឡើងប្រភេទក្របខ័ណ្ឌស្របតាមអតីតភាពការងារ និងកម្រិតសញ្ញាបត្រ ជាករណីពិសេសដល់លោក **ម៉ូយ សីឡាំង** ពីឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីក្រមការ មកឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ការ.១៦៧.៧៣៨

លេខ: ៧៦១៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៤៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** លុបឈ្មោះឯកឧត្តម **អ៊ិច សេង** ឧត្តមមន្ត្រីថ្នាក់លេខ ៥ អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ចេញពីក្របខណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី ដោយមូលហេតុសាមីខ្លួនទទួលមរណភាព ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ ២០១៦*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

ការស. ១៦០៧. ៧៣៥

លេខ: ៧១៤ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ,ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៦ )

**ប្រោសព្រះរាជទាន**

នូវ

**ក**-គ្រឿងឥស្សរិយយស **ជាតូបការ**

**ចំពោះ**

| | | | |
|---|---|---|---|
| ១ - | លោកឧត្តមសេនីយ៍ត្រី | **សំឃិត** | **វៀន** |
| ២ - | លោកឧត្តមអគ្គានុរក្ស.៣ | **ត្រី** | **ម៉ុនថា** |

**ខ**-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

**ចំពោះ**

| | | | | |
|---|---|---|---|---|
| ១ - | ឯកឧត្តម | **ហាក់** | **ចាន់នី** | |
| ២ - | ឯកឧត្តម | **ហ៊ីង** | **ស៊ីដេត** | |
| ៣ - | លោកឧត្តមអគ្គានុរក្ស.២ | **ឡា** | **មនោរិទ្ធ** | អត្តលេខ 0024 |
| ៤ - | លោកឧត្តមសេនីយ៍ត្រី | **សុខ** | **សុគន្ធ** | អត្តលេខ 09043 |
| ៥ - | លោកវរសេនីយ៍ឯក | **ញ៉ែម** | **តារា** | អត្តលេខ 03715 |
| ៦ - | លោក | **តូច** | **វណ្ណារិទ្ធ** | |
| ៧ - | លោក | **ឈាវ** | **ឈុន** | |
| ៨ - | លោក | **ហេង** | **រតនៈ** | |
| ៩ - | លោក | **ភា** | **សាជាត** | |
| ១០ - | លោក | **ប៊ឹង** | **ហេង** | |
| ១១ - | លោក | **សុខ** | **គឹមសាន** | |
| ១២ - | លោក | **ជីវ** | **ប៊ុនលី** | |
| ១៣ | លោក | **គង់** | **រតនា** | |
| ១៤ - | លោកស្រី | **អ៊ុម** | **ស៊ីវហុង** | |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS
ក្រសួងព្រះបរមរាជវាំង

១៥ - លោក ជា ពន្ធ
១៦ - លោក ឡុង សុភ័ក្រ្ត
១៧ - លោក ទូច សម្បត្តិ
១៨ - លោក ឡេង ចន្រ្ទា
១៩ - លោក ស្រ៊ុន ធីងឡេង
២០ - លោក សេង ណារិន

**គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍**

**ចំពោះ**

១ - លោក ឃិន សុខិនចិន្តា
២ - លោក ជា សុវី
៣ - លោក ឈេង សុវណ្ណជា
៤ - លោក ម៉ិច ស៊ីយុន
៥ - លោក មាស សុភាព
៦ - លោក ឡាង គីរី
៧ - លោក យក់ សទ្ធាគ
៨ - លោកវរសេនីយ៍ត្រី អេលីត ដាវីត អត្តលេខ 61733
៩ - លោក ខន សុវិធី
១០ - លោក នៅ វន្ធី
១១ - លោក អ៊ុយ សោភា
១២ - លោក ប៉ែន ទូចវណ្ណះ

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

**ចំពោះ**

១ - លោក ម៉ៅ ផល្លីន
២ - លោក គង់ ខេមរា
៣ - លោក ឡុញ ច័ន្ទចេតនា
៤ - លោកស្រី ឈុន ដាវី
៥ - លោក យស អូន
៦ - លោក ពៅ វិបុល
៧ - លោកវរសេនីយ៍ទោ ជា តារា
៨ - លោក មីន កុម្ភៈ
៩ - លោក មីន រតនៈ
១០ - លោកស្រី មិល សិរីសទ្ធា
១១ - លោកវេជ្ជបណ្ឌិត នៅ ម៉ឹង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

| | | | | |
|---|---|---|---|---|
| ១២ - | លោកវេជ្ជបណ្ឌិត | ម៉ក់ | គីមលី | |
| ១៣ - | លោកវេជ្ជបណ្ឌិត | ពិន | សាវ៉ាត | |
| ១៤ - | លោក | PIOTR | SASIN | |
| ១៥ - | លោក | គ្រួច | បូរីសីហា | |
| ១៦ - | លោក | ខួន | សុវណ្ណា | |
| ១៧ - | លោកស្រី | ស៊ុន | ចាន់ស្មើ | |

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

**ចំពោះ**

| | | | | |
|---|---|---|---|---|
| ១ - | លោកស្រី | អ៊ុន | សុគន្ធីតា | |
| ២ - | លោក | អេ | ម៉ុនថន | |
| ៣ - | លោកវរសេនីយ៍ទោ | ហេង | ឌីលុច្ស | អត្តលេខ 55058 |
| ៤ - | លោកស្រី | វ៉ាន់ | ស៊ីណា | |
| ៥ - | លោកស្រី | ឈឿន | ម៉ានីន | |
| ៦ - | លោក | សាម | ពិសិដ្ឋ | |
| ៧ - | លោកអនុសេនីយ៍ទោ | មាស | ចាន់ថន | អត្តលេខ 70867 |
| ៨ - | លោកអនុសេនីយ៍ទោ | សេង | រ័ត្ននរិទ្ធ | អត្តលេខ 68441 |

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦*
*ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់*
*ប្រមុខរដ្ឋស្តីទី*

៣៧. ១៦០៧.៧៣៦

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខៈ ៧៦៨.ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៤៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ជាកិច្ចបច្ឆាមរណៈ**

**ចំពោះ**

**សពឧបាសិកា ប៉ិច ឡឿង**

**នូវ**

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ**

៣រ៧. ១២០៧. ៧៣៧
បានប្រថាប់ព្រះរាជលញ្ឆករហើយ
*ធ្វើនៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៦*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ០២៧/១៦ រ. ចច
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីវង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧/៤១

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦ )

## ត្រាស់បង្គាប់

**តែងតាំង :**

១- លោក **ជា រិទ្ធី**
២- លោក **ខេង សុហ្វីណេ**
៣- លោក **សៀក សុគ័ណ្ឌ**
៤- លោក **ខេង រ៉ូប៊ីត**
៥- លោក **សៀក គីមសាត**

ជា

**ឧកញ៉ា**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពរម. ១៦០៧.៧៣៧

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខ: ៧៦៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៣០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៦

**ត្រាស់បង្គាប់**

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **កៅ ម៉ិនសុខ** អត្តលេខ **០១១១១** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៣រ៧.១៦០៧.៧៣៧

លេខ: ៧៥៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៣១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ :

១- ឧត្តមសេនីយ៍ទោ **មួង សុភា** អត្តលេខ ០០៤៣២៩

២- ឧត្តមសេនីយ៍ទោ **មាស សុចន្ថា** អត្តលេខ ០០៤៣៣០ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ករ. ១៦០៧. ៧៤០

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខៈ ៧៤០ ស.ណ
**សំណៅចែលមានគម្លៃឯការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៣៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងថ្នាក់ ជាករណីពិសេសដល់លោកជំទាវ **ស៊ឹម ខេងខាំ** ពីឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤ មកឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសុខាភិបាល ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៣៧.១៦០៧.៧៤១

លេខៈ ៧២៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៣៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានគុណជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ជូននាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ :

| | | | | |
|---|---|---|---|---|
| ១- ឧត្តមសេនីយ៍ត្រី | **ម៉ុក** | **ប៊ុនឈាង** | អត្តលេខ | **០២១៧** |
| ២- ឧត្តមសេនីយ៍ត្រី | **រុន** | **សុវណ្ណា** | អត្តលេខ | **៥៥៩៨៦** |
| ៣- ឧត្តមសេនីយ៍ត្រី | **សំ** | **វីរៈ** | អត្តលេខ | **០១៤០៩** |
| ៤- ឧត្តមសេនីយ៍ត្រី | **សៀង** | **យូដារ៉ាត់** | អត្តលេខ | **៥៤០៣៧** |
| ៥- ឧត្តមសេនីយ៍ត្រី | **យូ** | **សារ៉ុំ** | អត្តលេខ | **៧១៨៦៦** |
| ៦- ឧត្តមសេនីយ៍ត្រី | **សើរ** | **ចន្ធូ** | អត្តលេខ | **០៥៣២៤** |
| ៧- ឧត្តមសេនីយ៍ត្រី | **សំ** | **ដារ៉ា** | អត្តលេខ | **០៧៨៨៨** ។ |

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣រល.១៦០៧.៧៤២

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខៈ ៧៤១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៣៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **អានតុន ការ៉ាគា** ( ANTON CARAGEA ) ប្រធានក្រុមប្រឹក្សាទេសចរណ៍និងពាណិជ្ជកម្មអឺរ៉ុប ជាឯកអគ្គរាជទូតសុឆន្ទៈទេសចរណ៍កម្ពុជា ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៣រល. ១៦០៧. ៧៤៣

លេខៈ ៧២៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៣៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ចំនួន ០៤ រូប :

១- ឯកឧត្តម **អ៊ាង សុផល្លែត** ពី អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មកជា **អនុរដ្ឋលេខាធិការ** ក្រសួងបរិស្ថាន

២- ឯកឧត្តម **ស៊ូ ខនឫទ្ធីគុណ** ពី ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មកជា **អនុរដ្ឋលេខាធិការ** ក្រសួងបរិស្ថាន

៣- ឯកឧត្តម **ចាយ សាមិត្ត** ជា **អនុរដ្ឋលេខាធិការ** ក្រសួងបរិស្ថាន

៤- ឯកឧត្តម **ជា សំអាង** ជា **អគ្គនាយក** នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន ជំនួសឯកឧត្តម **ចាយ សាមិត្ត** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ការ. ១២០៧. ៧៤៦

លេខៈ ៧៣៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៣៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់លោកវរសេនីយ៍ឯក **ប្រាក់ វ៉ូហ្សា** អត្តលេខ **០៥២៣៩** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ករ. ១៦០៧. ៧៤៧

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខ: ៧៣៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៣៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦ )

**ប្រោសព្រះរាជទាន**

**នូវ**

**ក.** គ្រឿងឥស្សរិយយស **ជាតូបការ** :

១-ឯកឧត្តម **សៅ ឡែន**　　២-លោកជំទាវ **នុត យឹម**

៣-ឧកញ៉ា **ជា ចំណាន**　　៤-លោក **អន នាង**

៥-លោកឧត្តមសេនីយ៍ត្រី **អ៊ុច ប៊ុនថន**　　៦-លោកឧត្តមសេនីយ៍ត្រី **សុខ ចាន់**

**ខ.** គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជាថ្នាក់ មហាសេរីវឌ្ឍន៍** :

១-លោកឧត្តមសេនីយ៍ត្រី **ស រដ្ឋា** អត្តលេខ ៥៤៨៥៧　　២-លោកវរសេនីយ៍ឯក **ទ៉ាន់ ពិសិដ្ឋ** អត្តលេខ ០៧៦៦៦

៣-លោកវរសេនីយ៍ឯក **ខួន ម៉ុង** អត្តលេខ ០៥០៨២　　៤-លោកវរសេនីយ៍ត្រី **ប៉ូ សេងលាង** អត្តលេខ ០៥៣១៤

៥-លោក **រស់ ណារិទ្ធ**　　៦-លោក **អ៊ី ឫទ្ធី**

៧-លោក **ទូន សុគន្ធ**　　៨-លោក **ញ៉ែម សុខជា**

៩-លោក **អ៊ុយ សាគុណ**　　១០-លោក **ស ឈុនហុង**

១១-លោក **ស ចាន់ថូ**　　១២-លោក **មាស ពិសិដ្ឋ**

១៣-លោក **និល ប៊ុនធឿន**　　១៤-លោក **ឡាយ សាយ**

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជាថ្នាក់ មហាសេនា** :

១-លោក **នួន សុភ័ណ្ឌ**　　២- លោក **ផាត សុផានិត**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣-លោក ទ៉ាន់ សុភាព ៤-លោក ឈួន ខេមរិទ្ធិ

៥-លោក អ៊ុន វីលីយ៉ា ៦-លោក គង់ អ៊ីន់

៧-កញ្ញា និត វណ្ណថាវ៉េន ៨-លោក ហ៊ុយ អ៊ិត

៩-លោកវរសេនីយ៍ទោ ឡុង មិថុនា អត្តលេខ ៧៧៨៥៧

**ឃ.** គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១-លោកអនុសេនីយ៍ឯក **ជិន ផានិត** អត្តលេខ ៦១៨៨៩

២-លោកអនុសេនីយ៍ទោ **ប៉ូ វណ្ណារិទ្ធិ** អត្តលេខ ៧៣១១១

៣-លោកអនុសេនីយ៍ទោ **គា ឧត្តម** អត្តលេខ ៧២០៨៦

**ង.** គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១-លោកវរសេនីយ៍ឯក **ហូ គីមលី** អត្តលេខ៦៨២៩៤

២-លោកវរសេនីយ៍ទោ **ម៉ៅ គន្ធា** អត្តលេខ ៥៧២៧៨

**ច.** គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១-លោក **ហាស់ ពណ្ណាភ័ណ** ២-លោក **ម៉ែន ជា**

៣-លោក **សរ បូរីរក្ស** ៤-លោក **ព្រិល គង់**

៥-លោក **ហ៊ុន ចន្ទ្រា**

**ឆ.** គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១-លោកអនុសេនីយ៍ឯក **ឡៃ ឡុងឌី** អត្តលេខ ៦២៤៩៨

២-លោកអនុសេនីយ៍ទោ **ឃីម លាងហួរ** អត្តលេខ ៦៩១២៩

៣-លោកអនុសេនីយ៍ត្រី **គា សំអឿន** អត្តលេខ ៧៧៣៥៦

៤-លោកអនុសេនីយ៍ត្រី **ចៅង ឈុនលី** អត្តលេខ ៧៧៣៥៤

៥-លោក **គង់ គីមស្រៀន** ៦-លោក **មុនី សីហា**

**ជ.** គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** :

លោកវរសេនីយ៍ឯក **គាំ ឧុទ្ធិគុណ** អត្តលេខ ០៧០៥៨

*ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៦*

*ក្នុងព្រះបរមនាម និងតាមព្រះរាជព្រាសបង្គាប់*

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៣.៧.១៦០៧.៧៤៧

លេខ:៧៣៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែ សម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅដូចខាងក្រោម៖

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំមុខងារនិងភារកិច្ចរបស់អង្គភាពនានានៃក្រសួងអប់រំ យុវជន និងកីឡា
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារក្នុងវិស័យអប់រំ យុវជន និងកីឡា។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើវិស័យអប់រំ យុវជន និងកីឡានៅគ្រប់អង្គភាពថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា។

## ជំពូកទី២

## បេសកកម្មនិងរចនាសម្ព័ន្ធ

**មាត្រា៤ .-**

ក្រសួងអប់រំ យុវជន និងកីឡាមានបេសកកម្មដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើនក្នុងតំបន់និងសកលលោក។

**មាត្រា៥ .-**

ក្រសួងអប់រំ យុវជន និងកីឡាមានមុខងារនិងភារកិច្ចដូចតទៅ៖

- កំណត់នយោបាយអប់រំ យុវជន និងកីឡា សំដៅធានាការអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព
- កសាងនីតិក្រមសម្រាប់អភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា
- កសាងផែនការអនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃនយោបាយអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍធនធានមនុស្ស ព្រមទាំងលើកទិសដៅនិងវិធានការកែលម្អជាបន្តបន្ទាប់តាមគ្រប់មុខជំនាញ
- លើកកម្ពស់គុណភាពវិស័យអប់រំ យុវជន និងកីឡាឱ្យឆ្លើយតបទៅនឹងដំណាក់កាលនីមួយៗនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិនិងអន្តរជាតិ ដើម្បីកសាងសមត្ថភាពខាងចំណេះដឹង បំណិន ចរិយា សីលធម៌ និងចេះរួមរស់ជាមួយគ្នា
- តម្រង់ទិសវិជ្ជាជីវៈ បំណិនជីវិត និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅគ្រប់ភូមិសិក្សា
- លើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាដោយធានាសមធម៌ និងបរិយាបន្ន

- អភិវឌ្ឍធនធានមនុស្សលើផ្នែកបច្ចេកសហគ្រិនភាពនិងអប់រំបច្ចេកទេសក្នុងតំបន់
- សិក្សាលើសំណើបង្កើត បើក បិទ រំលាយបញ្ចូលគ្នា ជំនាញថ្មី បំបែក ប្រែក្លាយ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- សិក្សាលើសំណើទទួលស្គាល់ការបង្កើត បើក បិទ រំលាយបញ្ចូលគ្នា ជំនាញថ្មី បំបែក ប្រែក្លាយ គ្រឹះស្ថានឧត្តមសិក្សាឯកជន
- លើកកម្ពស់ការស្រាវជ្រាវនិងបច្ចេកវិទ្យាព័ត៌មានដើម្បីអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា
- គ្រប់គ្រង ត្រួតពិនិត្យ វាយតម្លៃដំណើរការសិក្សា ការនិពន្ធ ការផ្សាយ ការនាំចូលសៀវភៅសិក្សា និងឯកសារពាក់ព័ន្ធនឹងការបង្រៀននិងរៀនគ្រប់កម្រិតសិក្សា គ្រប់ភូមិសិក្សា និងដាក់ពិន័យ
- ពិនិត្យលើការផ្តល់ បដិសេធ ដកហូតវិញ្ញាបនបត្រឬសញ្ញាបត្រ និងវាយតម្លៃកម្រិតវិញ្ញាបនបត្រឬសញ្ញាបត្រ ចេញដោយគ្រឹះស្ថានសិក្សានានា ទាំងក្នុង ទាំងក្រៅប្រទេស
- ផលិតនិងត្រួតពិនិត្យការផ្សព្វផ្សាយព័ត៌មានអប់រំ ការផ្សាយពាណិជ្ជកម្មសិក្សាតាមគ្រប់រូបភាពពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន និងកីឡា
- អភិវឌ្ឍការងារយុវជននិងការងារអប់រំកាយនិងកីឡាដោយកំណត់វិធានគ្រប់គ្រង អប់រំ បណ្តុះបណ្តាល និងបំប៉នបច្ចេកទេស
- បង្កើនការយល់ដឹងអំពីវប្បធម៌ជាតិនិងវប្បធម៌អន្តរជាតិ
- គ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង អប់រំ យុវជន និងកីឡា
- ពិនិត្យនិងផ្តល់យោបល់លើគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន និងកីឡា
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៦ .-**

ក្រសួងអប់រំ យុវជន និងកីឡា មានរចនាសម្ព័ន្ធដូចខាងក្រោម៖

I. ថ្នាក់កណ្តាល

ក- អគ្គាធិការដ្ឋាន រួមមានអង្គភាពចំណុះ៖

- នាយកដ្ឋានធានាគុណភាពអប់រំ
- អធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានកិច្ចការប្រឡង។

ខ- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ រួមមានអង្គភាពចំណុះ៖

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានហិរញ្ញវត្ថុ
- នាយកដ្ឋានសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ

- នាយកដ្ឋានទំនាក់ទំនងវប្បធម៌និងអាហារូបករណ៍
- នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន
- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានសំណង់
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន។

គ- អគ្គនាយកដ្ឋានអប់រំ រួមមានអង្គភាពចំណុះ៖

- នាយកដ្ឋានអប់រំកុមារតូច
- នាយកដ្ឋានបឋមសិក្សា
- នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ
- នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
- នាយកដ្ឋានសុខភាពសិក្សា
- នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
- នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ
- នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ
- នាយកដ្ឋានអប់រំពិសេស
- គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ។

ឃ- អគ្គនាយកដ្ឋានឧត្តមសិក្សា រួមមានអង្គភាពចំណុះ៖

- នាយកដ្ឋានឧត្តមសិក្សា
- នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ។

ង- អគ្គនាយកដ្ឋានយុវជន រួមមានអង្គភាពចំណុះ៖

- នាយកដ្ឋានយុវជន
- នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល។

ច- អគ្គនាយកដ្ឋានកីឡា រួមមានអង្គភាពចំណុះ៖

- នាយកដ្ឋានអប់រំកាយនិងកីឡា
- នាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស និស្សិត
- មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា
- វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា។

ឆ- អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ រួមមានអង្គភាពចំណុះ៖

- នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ
- នាយកដ្ឋានគោលនយោបាយ
- នាយកដ្ឋានផែនការ
- នាយកដ្ឋានពិនិត្យ តាមដាន និងវាយតម្លៃ។

ជ- អង្គភាពស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋមន្ត្រី៖

- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ខុទ្ទកាល័យ។

II. អង្គភាពមូលដ្ឋាន
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

III. គ្រឹះស្ថានឧត្តមសិក្សា វិទ្យាស្ថាននានា មានឋានៈស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡាៈ
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សាកលទ្យាល័យជាតិគ្រប់គ្រង
- សាកលវិទ្យាល័យស្វាយរៀង
- សាកលវិទ្យាល័យមានជ័យ
- សាកលវិទ្យាល័យបាត់ដំបង
- សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ
- សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ
- សាកលវិទ្យាល័យក្រចេះ
- វិទ្យាស្ថានជាតិអប់រំ
- វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

IV. គ្រឹះស្ថានសិក្សា វិទ្យាស្ថាននានា និងមជ្ឈមណ្ឌល មានឋានៈស្មើនាយកដ្ឋាន ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡាៈ
- វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល
- វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ។

អង្គការលេខរបស់ក្រសួងអប់រំ យុវជន និងកីឡា ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ។

## ជំពូកទី៣
## អគ្គាធិការដ្ឋាន

**មាត្រា៧ .-**

អគ្គាធិការដ្ឋាន មានតួនាទីនិងភារកិច្ចត្រួតពិនិត្យលើគ្រប់ឋានានុក្រមរដ្ឋបាល និងការងារគ្រប់គ្រងអប់រំ ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង ស្តីពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ច និងលើកសំណើវិធានការកែលម្អ។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូបនិងមានអគ្គាធិការរងមួយចំនួនតាមការចាំបាច់។

**មាត្រា៨ .-**

នាយកដ្ឋានធានាគុណភាពអប់រំ មានតួនាទីនិងភារកិច្ចដូចតទៅៈ
- សិក្សា ស្រាវជ្រាវ វិភាគ និងវាយតម្លៃគុណភាពនិងប្រសិទ្ធភាពវិស័យអប់រំ
- ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សា និងការប្រើសម្ភារៈសិក្សានានា នៅគ្រប់គ្រឹះស្ថានសិក្សារដ្ឋ និងឯកជន
- ពិនិត្យ តាមដាន វាយតម្លៃលើការអនុវត្តឬការបំពេញលក្ខខណ្ឌស្តង់ដារនៃអប់រំនៅគ្រប់គ្រឹះស្ថានសិក្សានានា/.

- ធានាការវាស់ស្ទង់សមត្ថភាពកម្រិតសមមូល
- ពិនិត្យតាមដានលើការអនុវត្តជំនាញយុវជននិងកីឡា
- ពិនិត្យ តាមដាន និងលើកសំណើដោះស្រាយករណីមិនប្រក្រតីនានាដែលពាក់ព័ន្ធនឹងបច្ចេកទេសអប់រំ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គាធិការប្រគល់ជូន។

នាយកដ្ឋានធានាគុណភាពអប់រំ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា៩ .-**

អធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ធ្វើអធិការកិច្ចលើដំណើរការនៃការងារគ្រប់គ្រងបុគ្គលិក រដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋនៅតាមអង្គភាពនិងគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន
- ត្រួតពិនិត្យនិងលើកសំណើដោះស្រាយករណីទាំងឡាយដែលពាក់ព័ន្ធនឹងការងាររដ្ឋបាល និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គាធិការប្រគល់ជូន។

អធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ដឹកនាំដោយអធិការមួយរូបនិងមានអធិការរងមួយចំនួនតាមការចាំបាច់។

**មាត្រា១០ .-**

នាយកដ្ឋានកិច្ចការប្រឡង មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំផែនការនិងសិក្សាស្រាវជ្រាវ វិភាគ វាយតម្លៃ និងបូកសរុបកិច្ចការប្រឡងគ្រប់ប្រភេទ
- រៀបចំយន្តការនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការប្រឡងគ្រប់ប្រភេទ
- គ្រប់គ្រងដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃការប្រឡងចំណេះទូទៅ និងការអប់រំបច្ចេកទេស ការប្រឡងជ្រើសរើសសិស្សពូកែថ្នាក់ជាតិនិងអន្តរជាតិ
- សហការនិងសម្របសម្រួលការប្រឡងជ្រើសរើសសិស្ស និស្សិតអាហារូបករណ៍ក្នុងនិងក្រៅប្រទេស ការប្រឡងជ្រើសរើសនិងការប្រឡងបញ្ចប់គ្រូបង្រៀនគ្រប់ប្រភេទនិងគ្រប់កម្រិត ការប្រឡងប្រជែងផ្ទៃក្នុងដើម្បីប្តូរក្របខណ្ឌមន្ត្រីរាជការ និងការប្រឡងផ្សេងៗទៀត
- សម្របសម្រួលនិងធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័ននានាពាក់ព័ន្ធនឹងកិច្ចការប្រឡងគ្រប់ប្រភេទ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គាធិការប្រគល់ជូន។

នាយកដ្ឋានកិច្ចការប្រឡង ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

## ជំពូកទី៤
## អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

**មាត្រា១១ .-**

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចសម្របសម្រួលនិងគ្រប់គ្រងកិច្ចការរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ ទំនាក់ទំនងវប្បធម៌ក្នុងតំបន់និងលើសកលលោក និងការងារបច្ចេកវិទ្យាព័ត៌មាន។

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ដឹកនាំដោយអគ្គនាយកមួយរូបនិងមានអគ្គនាយករងមួយចំនួនតាមការចាំបាច់។

**មាត្រា១២ .-**

នាយកដ្ឋានរដ្ឋបាល មានតួនាទីនិងភារកិច្ចដូចតទៅៈ

- សម្របសម្រួលនិងធ្វើទំនាក់ទំនងសកម្មភាពរដ្ឋបាលលើគ្រប់ផ្នែករវាងក្រសួងជាមួយនឹងអង្គភាពថ្នាក់កណ្តាល អង្គភាពមូលដ្ឋាន អន្តរក្រសួង និងអាជ្ញាធរដែនដី
- គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាលរបស់ក្រសួងនិងអន្តរក្រសួង
- រៀបចំសេវាទទួលនិងផ្តល់ព័ត៌មាន
- ថែទាំនិងទុកដាក់ឯកសាររដ្ឋបាលគ្រប់ប្រភេទ
- គ្រប់គ្រងទីតាំងក្រសួង ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល សណ្តាប់ធ្នាប់ គ្រប់គ្រងត្រា និងការងារសង្គម
- គ្រប់គ្រងព័ត៌មានគ្រប់ផ្នែក ធ្វើរបាយការណ៍ និងរៀបចំសន្និបាតការងារអប់រំ យុវជន និងកីឡា
- រៀបចំបែបបទនិងលើកសំណើ ដើម្បីផ្តល់មេដាយការងារនិងគ្រឿងឥស្សរិយយសផ្សេងៗជូនថ្នាក់ដឹកនាំនិងមន្ត្រីរាជការ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានរដ្ឋបាល ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា១៣ .-**

នាយកដ្ឋានបុគ្គលិក មានតួនាទីនិងភារកិច្ចដូចតទៅៈ

- គ្រប់គ្រងក្របខណ្ឌ ការងាររដ្ឋបាល បុគ្គលិកអប់រំ និងភ្នាក់ងាររាជការរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានទំនាក់ទំនងជាមួយនឹងក្រសួងមុខងារសាធារណៈ
- រៀបចំបែបបទជ្រើសរើស តែងតាំង ដំឡើងថ្នាក់ ដំឡើងឋានន្តរសក្តិ ចូលនិវត្តន៍ ផ្លាស់ប្តូរ លើកសរសើរ លើកទឹកចិត្ត ទណ្ឌកម្ម និងលុបឈ្មោះបុគ្គលិកអប់រំ
- រៀបចំសំណុំលិខិត ស្ថិតិបុគ្គលិក និងគ្រប់គ្រងព័ត៌មានបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា
- ធ្វើកម្មវិធីតំណែងឯកទេសនិងធនធានមនុស្ស និងការងារវិភាគមុខងារ
- រៀបចំយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រលើការងារគ្រប់គ្រង
- វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិកអប់រំ
- រៀបចំបៀវត្ស ប្រាក់កម្រៃ និងរបបឧបត្ថម្ភផ្សេងៗ

- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានបុគ្គលិក ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា១៤ .-**

នាយកដ្ឋានហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំផែនការហិរញ្ញវត្ថុរយៈពេលមធ្យមសម្រាប់វិស័យអប់រំ យុវជន និងកីឡា
- ប្រមូលតម្រូវការថវិការបស់អង្គភាពរដ្ឋបាលកណ្តាល និងបូកសរុបរៀបចំគម្រោងចំណូល និងចំណាយថវិកាប្រចាំឆ្នាំ
- រៀបចំសំណើសុំថវិកាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយនិងបើកផ្តល់ បែងចែកថវិកាជូនអង្គភាពរដ្ឋបាលកណ្តាលនិងរាជធានី ខេត្ត
- ពិនិត្យតាមដានការគ្រប់គ្រង និងប្រើប្រាស់ថវិកាគ្រប់ជំពូកចំណូល ចំណាយរបស់អង្គភាពរដ្ឋបាលកណ្តាលនិងរាជធានី ខេត្ត
- រៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ណែនាំដល់ការងារគ្រប់គ្រង និងប្រើប្រាស់ថវិកាគ្រប់ជំពូក
- តាមដានរាល់សកម្មភាពចំណូល ចំណាយ និងរៀបចំរបាយការណ៍បូកសរុបស្តីពីស្ថានភាពចំណូល ចំណាយថវិកាគ្រប់ប្រភេទរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ពិនិត្យតាមដានការគ្រប់គ្រង និងប្រើប្រាស់គណនីគ្រប់ប្រភេទនៅរតនាគារជាតិ និងធនាគារ
- កសាងនិងពង្រឹងសមត្ថភាពមន្ត្រីជំនាញដែលពាក់ព័ន្ធនឹងការងារគណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ
- រៀបចំប្រព័ន្ធគ្រប់គ្រងប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុសម្រាប់អង្គភាពរដ្ឋបាលកណ្តាលនិងរាជធានី ខេត្ត
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា១៥ .-**

នាយកដ្ឋានសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ប្រមូលតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រង និងជួសជុលសម្ភារៈនិងបរិក្ខារ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភណ្ឌ
- គ្រប់គ្រងយានដ្ឋាននិងយានយន្តរបស់រដ្ឋ ដែលក្រសួងប្រគល់ជូន
- ទទួលនិងបែងចែកសម្ភារៈបរិក្ខារជូនដល់អង្គភាពចំណុះក្រសួង និងរាជធានី ខេត្ត
- គ្រប់គ្រងចំណូលបានមកពីចលនទ្រព្យនិងអចលនទ្រព្យ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា១៦ .-**

នាយកដ្ឋានទំនាក់ទំនងវប្បធម៌និងអាហារូបករណ៍ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនិងអង្គការនានាក្នុងតំបន់និងលើសាកលលោក
- សម្របសម្រួលការងារក្រៅក្រសួងនិងការងារអន្តរជាតិ
- រៀបចំឯកសារនិងពិធីការក្នុងកិច្ចសហប្រតិបត្តិការក្នុងនិងក្រៅប្រទេស
- ជ្រើសរើសនិងគ្រប់គ្រងសិស្ស និស្សិតអាហារូបករណ៍ និងកម្មសិក្សាការីខ្មែរនៅបរទេស និងគ្រប់គ្រងនិស្សិតអាហារូបករណ៍បរទេសនៅកម្ពុជា
- ធ្វើស្ថិតិសិស្ស និស្សិតអាហារូបករណ៍បញ្ចប់ការសិក្សាមកពីបរទេស ដើម្បីបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ អង្គការអន្តរជាតិនានាក្នុងតំបន់និងលើសាកលលោក
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានទំនាក់ទំនងវប្បធម៌និងអាហារូបករណ៍ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា១៧ .-**

នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ប្រមូលផ្ដុំព័ត៌មានសាធារណៈនិងផ្សព្វផ្សាយព័ត៌មានអប់រំ យុវជន និងកីឡា
- ផលិតឯកសារអប់រំ ព្រឹត្តិបត្រព័ត៌មាន និងទស្សនាវដ្ដីអប់រំ
- ផ្សព្វផ្សាយចក្ខុវិស័យអាស៊ាននិងស៊ីមេអូ
- ធ្វើទំនាក់ទំនងការងារអប់រំ យុវជន និងកីឡា ជាមួយក្រសួង ស្ថាប័នជាតិ និងបណ្ដាប្រទេសសមាជិកអាស៊ាន ស៊ីមេអូ និងប្រទេសដៃគូ
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា១៨ .-**

នាយកដ្ឋាននីតិកម្ម មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ជាសេនាធិការរបស់ក្រសួងលើការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- រៀបចំតាក់តែងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយផ្សេងៗ ព្រមទាំងសហការជាមួយនឹងអង្គភាពពាក់ព័ន្ធ
- ពិនិត្យ ផ្ដល់យោបល់ កែសម្រួលលើទម្រង់និងខ្លឹមសារគតិយុត្តនៃសេចក្ដីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយផ្សេងៗ ដែលរៀបចំដោយអង្គភាពជំនាញនិងស្ថាប័ន[illegible]

- រៀបចំ ចងក្រង និងគ្រប់គ្រងទិន្នន័យគតិយុត្ត ក្នុងវិស័យអប់រំ យុវជន និងកីឡា
- បណ្តុះបណ្តាលនិងផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយជាធរមាន
- ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត
- គ្រប់គ្រងនិងតាមដានការងារវិវាទរបស់បុគ្គលិកអប់រំ និងលើកសំណើអំពីវិធានគតិយុត្តដែលពាក់ព័ន្ធជូនថ្នាក់ដឹកនាំសម្រេច
- ពិនិត្យនីត្យានុកូលភាពរាល់លិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងវិស័យអប់រំ យុវជន និងកីឡា
- សហការនិងសម្របសម្រួលការងារអភិបាលកិច្ចល្អនិងការងារវិមជ្ឈការនិងវិសហមជ្ឈការ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋាននីតិកម្ម ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា១៩ .-**

នាយកដ្ឋានសំណង់ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំបទដ្ឋានស្តង់ដានានាពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ប្រមូលផ្តុំទិន្នន័យពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- សិក្សាអំពីតម្រូវការអគារសិក្សា ដោយផ្អែកទៅលើទិន្នន័យរបស់សិស្សានុសិស្ស
- រៀបចំគំនូសប្លង់និងសិក្សាពីទំហំ ខ្នាត ផែនការលម្អិតបច្ចេកទេស ដែលពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ត្រួតពិនិត្យបច្ចេកទេសប្រតិបត្តិលទ្ធកម្មសាធារណៈលើគម្រោងសាងសង់ថ្មី ការងារជួសជុល និងត្រួតពិនិត្យការអនុវត្ត ការជួសជុល និងការសាងសង់អគារផ្សេងៗ
- ធ្វើសហប្រតិបត្តិការជាមួយនឹងបណ្តាអង្គការឬសប្បុរសជននានា លើផ្នែកបច្ចេកទេសនិងបទដ្ឋានផ្សេងៗ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានសំណង់ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា២០ .-**

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន មានតួនាទីនិងភារកិច្ចដូចតទៅ៖

- កសាងគោលនយោបាយ ផែនការសកម្មភាពសម្រាប់អនុវត្តការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន
- គ្រប់គ្រងការងារបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ក្នុងវិស័យអប់រំ យុវជន និងកីឡា
- ពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍
- ជំរុញនិងសម្របសម្រួលការអប់រំមិនផ្លូវការតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍
- បង្កើនប្រសិទ្ធភាពរដ្ឋបាលអប់រំតាមរយៈការបង្កើតនិងគ្រប់គ្រងបណ្តាញបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍
- គ្រប់គ្រង ថែទាំ និងធ្វើបច្ចុប្បន្នកម្មដែនគេហទំព័រ អនុគេហទំព័រក្រសួងអប់រំ យុវជន និងកីឡា
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង

- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

## ជំពូកទី៥
## អគ្គនាយកដ្ឋានអប់រំ

**មាត្រា២១ .-**

អគ្គនាយកដ្ឋានអប់រំមានតួនាទីនិងភារកិច្ចសម្របសម្រួល គ្រប់គ្រង និងអភិវឌ្ឍការអប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ ការអប់រំពិសេស ការអប់រំក្រៅប្រព័ន្ធ កម្មវិធីសិក្សា និងសៀវភៅសិក្សា សុខភាពសិក្សា ការបណ្តុះបណ្តាលនិងវិក្រឹតការ តម្រង់ទិសវិជ្ជាជីវៈ បំណិនជីវិត និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

អគ្គនាយកដ្ឋានអប់រំ ដឹកនាំដោយអគ្គនាយកមួយរូបនិងមានអគ្គនាយករងមួយចំនួន តាមការចាំបាច់។

**មាត្រា២២ .-**

នាយកដ្ឋានអប់រំកុមារតូច មានតួនាទីនិងភារកិច្ចដូចតទៅ៖

- អប់រំកុមារតូចពី០ឆ្នាំទៅ៧០(ចិតសិប)ខែ
- កសាងផែនការអប់រំនិងអភិវឌ្ឍកុមារតូចរយៈពេលវែង មធ្យម ខ្លី ដោយសហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងសហគមន៍
- កសាងគោលនយោបាយ គោលការណ៍ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីគ្រប់គ្រង និងអភិវឌ្ឍការងារអប់រំកុមារតូច
- គ្រប់គ្រង ត្រួតពិនិត្យ តាមដានថ្នាក់និងសាលាមត្តេយ្យសិក្សារដ្ឋនិងឯកជន
- ជំរុញការអភិវឌ្ឍមត្តេយ្យសហគមន៍ ទារកដ្ឋាន និងមត្តេយ្យសិក្សាខ្នងផ្ទះ
- ពិនិត្យ តាមដាន និងកែលម្អការអនុវត្តកម្មវិធីសិក្សានិងបច្ចេកទេសគរុកោសល្យ
- សិក្សាលើសំណើបង្កើត បើក ទទួលស្គាល់ បិទសាលាមត្តេយ្យសិក្សារដ្ឋនិងឯកជន និងទារកដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានអប់រំកុមារតូច ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា២៣ .-**

នាយកដ្ឋានបឋមសិក្សា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ធានាការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងបំណិនមូលដ្ឋានដំបូងចាំបាច់
- អភិវឌ្ឍសាលារៀន ថ្នាក់រៀន ការងារគ្រប់គ្រង និងបច្ចេកទេសសាលាបឋមសិក្សាសាធារណៈនិងឯកជនឱ្យស្របតាមកម្មវិធីសិក្សាគោល
- ពិនិត្យតាមដានដំណើរការសិក្សាអប់រំ និងបំផុសលើកទឹកចិត្តការអភិវឌ្ឍគ្រូ សាលារៀនបឋមសិក្សាសាធារណៈនិងឯកជន។

- សិក្សាលើសំណើសុំបង្កើត បើក ទទួលស្គាល់ បិទសាលារៀនបឋមសិក្សាសាធារណៈនិងឯកជន
- កសាងគោលនយោបាយ គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដើម្បីគ្រប់គ្រង និងអភិវឌ្ឍការងារអប់រំបឋមសិក្សា
- ពិនិត្យតាមដានការរីកចម្រើននិងលើកទិសដៅអភិវឌ្ឍបន្ត
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានបឋមសិក្សា ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា២៤ .-**

នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ធានាការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញ ដោយពង្រីកវិសាលភាពចំណេះដឹងនៅបឋមសិក្សានិងមានលក្ខណសម្បត្តិបន្តការសិក្សា
- អភិវឌ្ឍនិងគ្រប់គ្រងបច្ចេកទេសសាលារៀនមធ្យមសិក្សាចំណេះទូទៅសាធារណៈនិងឯកជន
- គ្រប់គ្រងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាប់ជាប្រចាំ
- កំណត់និយាមគរុកោសល្យ និងមូលដ្ឋានសម្ភារៈសម្រាប់អភិវឌ្ឍសាលារៀនមធ្យមសិក្សាចំណេះទូទៅសាធារណៈនិងឯកជន
- សិក្សាលើសំណើបង្កើត បើក ទទួលស្គាល់ បិទសាលារៀនមធ្យមសិក្សាចំណេះទូទៅសាធារណៈនិងឯកជន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា២៥ .-**

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងការងារអក្ខរកម្ម ក្រោយអក្ខរកម្ម និងកម្មវិធីសមមូល ដោយផ្តល់ចំណេះដឹងទូទៅ ជំនាញវិជ្ជាជីវៈ ជំនាញមុខរបរ
- កសាងកម្មវិធីសិក្សា ឯកសាររៀននិងបង្រៀនសម្រាប់កម្មវិធីអក្ខរកម្ម ក្រោយអក្ខរកម្ម និងកម្មវិធីសមមូលគ្រប់ភូមិសិក្សា
- បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងមុខរបរដល់ប្រជាពលរដ្ឋគ្រប់ភេទ គ្រប់វ័យ តាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍
- ពិនិត្យតាមដានដំណើរការសិក្សាក្នុងសាលារៀននិងថ្នាក់រៀនអប់រំក្រៅប្រព័ន្ធគ្រប់ប្រភេទ
- រៀបចំប្រព័ន្ធទិន្នន័យអប់រំក្រៅប្រព័ន្ធ
- ផ្សព្វផ្សាយព័ត៌មាននិងសម្របសម្រួលសកម្មភាពអប់រំក្រៅប្រព័ន្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការនានា
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង

- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា២៦ .-**

នាយកដ្ឋានសុខភាពសិក្សា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងនិងអភិវឌ្ឍកម្មវិធីអប់រំសុខភាព និងអនាម័យតាមគ្រឹះស្ថានសិក្សា
- គ្រប់គ្រងបន្ទប់សង្គ្រោះបឋមនៅតាមគ្រឹះស្ថានសិក្សា
- ពិនិត្យសុខភាពបុគ្គលិកអប់រំនិងអ្នកសិក្សា ដោយសហការជាមួយនឹងក្រសួងសុខាភិបាល
- ពិនិត្យ តាមដាន ស្រាវជ្រាវ និងលើកវិធានការទប់ស្កាត់ជំងឺរាតត្បាតនានាតាមគ្រឹះស្ថានសិក្សា
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានសុខភាពសិក្សា ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា២៧ .-**

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- អភិវឌ្ឍនិងផ្សព្វផ្សាយកម្មវិធីសិក្សាជាតិនិងកម្មវិធីបំណិនជីវិតឱ្យបានទូលំទូលាយ
- អភិវឌ្ឍឯកសារគរុកោសល្យ បច្ចេកទេសបណ្ណាល័យ និងសម្ភារៈឧបទេស
- ពិនិត្យតាមដានការនិពន្ធ ការផ្សព្វផ្សាយ និងការនាំចូលសម្ភារៈសិក្សា សៀវភៅសិក្សា និងឯកសារពាក់ព័ន្ធនឹងការបង្រៀននិងការរៀន
- ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាគោល ការគ្រប់គ្រងបណ្ណាល័យ និងកម្មវិធីបំណិនជីវិត
- ណែនាំអំពីគោលការណ៍អភិវឌ្ឍនិងផ្គត់ផ្គង់សៀវភៅសិក្សា
- សិក្សាស្រាវជ្រាវខ្លឹមសារកម្មវិធីសិក្សាជាតិនិងអន្តរជាតិ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា២៨ .-**

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- កសាងផែនការបណ្តុះបណ្តាលក្របខណ្ឌបុគ្គលិកអប់រំ ដោយសហការជាមួយនឹងអង្គភាពពាក់ព័ន្ធ
- រៀបចំកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ
- គ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យនិងវិក្រឹតការ រាជធានី ខេត្ត និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម
- ពិនិត្យតាមដានសមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិកអប់រំ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង។

- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា២៩ .-**

នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- កសាងគោលនយោបាយសម្រាប់អភិវឌ្ឍការងារបណ្តុះបណ្តាលអប់រំបច្ចេកទេសវិជ្ជាជីវៈ
- កសាងផែនការ សកម្មភាពបណ្តុះបណ្តាល និងតម្រូវការមុខជំនាញ សំដៅធានាដល់ប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំដល់អ្នកសិក្សានៅតាមសហគមន៍
- ពិនិត្យតាមដានដំណើរការតម្រង់ទិសវិជ្ជាជីវៈ បំណិនជីវិត និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមគ្រឹះស្ថានសិក្សា
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា៣០ .-**

នាយកដ្ឋានអប់រំពិសេស មានតួនាទីនិងភារកិច្ចដូចតទៅ៖

- កសាងគោលនយោបាយ ផែនការសកម្មភាពដើម្បីគ្រប់គ្រងនិងអភិវឌ្ឍការងារអប់រំពិសេស
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអប់រំពិសេស
- ជំរុញនិងបង្កឱកាសដល់ជនពិការនិងអ្នកសិក្សាពូកែដែលមានទេពកោសល្យឬបញ្ញាខ្ពស់
- អភិវឌ្ឍកម្មវិធីសិក្សានិងឯកសារអប់រំពិសេសគ្រប់ភូមិសិក្សា
- ពិនិត្យតាមដានដំណើរការសិក្សាអប់រំពិសេស
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានអប់រំពិសេស ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា៣១ .-**

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបរៀងនិងបោះពុម្ពកម្មវិធីសិក្សា សៀវភៅសិក្សា ឯកសារគរុកោសល្យ ផលិតសម្ភារៈឧបទេស ឯកសារផ្សេងៗរបស់ក្រសួង និងចែកផ្សាយឱ្យប្រើប្រាស់សម្រាប់ការអប់រំចំណេះទូទៅនិងអប់រំក្រៅប្រព័ន្ធ
- ត្រួតពិនិត្យការប្រើប្រាស់សៀវភៅសិក្សា ឯកសារគរុកោសល្យ សម្ភារៈឧបទេស ឱ្យ[illegible]តាមគោលការណ៍របស់ក្រសួង
- អនុវត្តក្នុងតួនាទីជាសហគ្រាសសាធារណៈតាមស្មារតីច្បាប់ អនុក្រឹត្យ លក្ខន្តិកៈ[illegible]

## ជំពូកទី៦
## អគ្គនាយកដ្ឋានឧត្តមសិក្សា

**មាត្រា៣២ .-**

អគ្គនាយកដ្ឋានឧត្តមសិក្សា មានតួនាទីនិងភារកិច្ចគ្រប់គ្រង សម្របសម្រួល និងអភិវឌ្ឍការងារបណ្តុះបណ្តាលកម្រិតក្រោយមធ្យមសិក្សា និងការងារស្រាវជ្រាវវិទ្យាសាស្ត្រ និងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ។

អគ្គនាយកដ្ឋានឧត្តមសិក្សា ដឹកនាំដោយអគ្គនាយកមួយរូបនិងមានអគ្គនាយករងមួយចំនួនតាមការចាំបាច់។

**មាត្រា៣៣ .-**

នាយកដ្ឋានឧត្តមសិក្សា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ធានាការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញ និងជំរុញការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ និងសង្គម
- កសាងគោលនយោបាយនិងផែនការអភិវឌ្ឍវិស័យឧត្តមសិក្សា
- គ្រប់គ្រងនិងសម្របសម្រួលការងារសិក្សានៃគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជន
- គ្រប់គ្រងទិន្នន័យនិងប្រព័ន្ធព័ត៌មានឧត្តមសិក្សា និងត្រួតពិនិត្យការផ្សព្វផ្សាយពាណិជ្ជកម្មសិក្សា
- ជ្រើសរើសនិស្សិតឱ្យចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៃឧត្តមសិក្សា
- ជ្រើសរើសនិងគ្រប់គ្រងនិស្សិតនៅក្នុងប្រទេស
- សិក្សាលើសំណើបង្កើត បើក បិទ រំលាយបញ្ចូលគ្នា ជំនាញថ្មី បំបែក ប្រែក្លាយ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- សិក្សាលើសំណើទទួលស្គាល់ការបង្កើត បើក បិទ រំលាយបញ្ចូលគ្នា ជំនាញថ្មី បំបែក ប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាឯកជន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានឧត្តមសិក្សា ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា៣៤ .-**

នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- លើកកម្ពស់និងគាំទ្រការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ ការច្នៃប្រឌិត និងការផលិត ដែលមានលក្ខណៈវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- កសាងគោលនយោបាយនិងផែនការសម្រាប់អភិវឌ្ឍការងារស្រាវជ្រាវវិទ្យាសាស្ត្រនិងបណ្តុះបណ្តាល
- ពិនិត្យ តាមដាន និងវាយតម្លៃលទ្ធផលនៃការស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកទេស
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

## ជំពូកទី៧
## អគ្គនាយកដ្ឋានយុវជន

**មាត្រា៣៥ .-**

អគ្គនាយកដ្ឋានយុវជន មានតួនាទីនិងភារកិច្ចសម្របសម្រួលនិងគ្រប់គ្រងកិច្ចការយុវជននិងកុមារនៅក្នុងក្របខណ្ឌក្រសួងនិងសង្គមជាតិ។

អគ្គនាយកដ្ឋានយុវជន ដឹកនាំដោយអគ្គនាយកមួយរូបនិងមានអគ្គនាយករងមួយចំនួនតាមការចាំបាច់។

**មាត្រា៣៦ .-**

នាយកដ្ឋានយុវជន មានតួនាទីនិងភារកិច្ចដូចតទៅ៖

- កសាងគោលនយោបាយ ផែនការ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីអភិវឌ្ឍការងារយុវជននិងកុមារ
- សហការជាមួយនឹងអង្គភាពពាក់ព័ន្ធនិងដៃគូអភិវឌ្ឍលើការងារយុវជននិងកុមារ
- បណ្តុះបណ្តាលបញ្ញា ស្មារតី និងបំផុសចិត្តគំនិតយុវជននិងកុមារ ឱ្យមានសីលធម៌រស់នៅថ្លៃថ្នូរ គិតគូរពីបញ្ហាបុគ្គលខ្លួនឯង គ្រួសារ សង្គម ប្រទេសជាតិ
- លើកកម្ពស់ចលនាប្រឡងប្រណាំងពលរដ្ឋល្អ កូនល្អ សិស្សល្អ មិត្តល្អរបស់កុមារនិងយុវជន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានយុវជន ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា៣៧ .-**

នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ណែនាំការបង្កើតនិងការរៀបចំដំណើរការអភិវឌ្ឍមជ្ឈមណ្ឌលយុវជន រាជធានី ខេត្ត
- សហការជាមួយនឹងអង្គភាពពាក់ព័ន្ធ ដើម្បីណែនាំនិងអប់រំយុវជនក្រៅសាលាឱ្យទទួលបានការបណ្តុះបណ្តាលជំនាញវគ្គខ្លីសម្រាប់ជីវភាពរស់នៅនិងបំណិនការងាររបស់ខ្លួន
- លើកកម្ពស់ការស្ម័គ្រចិត្តរបស់យុវជនក្នុងការចុះជួយការងារនៅតាមមូលដ្ឋាននានា
- សិក្សា ស្រាវជ្រាវ និងរៀបចំផែនការសម្រាប់ដំណើរការមជ្ឈមណ្ឌលជាតិ រាជធានី ខេត្ត
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

## ជំពូកទី៨
## អគ្គនាយកដ្ឋានកីឡា

**មាត្រា៣៨ .-**

អគ្គនាយកដ្ឋានកីឡា មានតួនាទីនិងភារកិច្ចគ្រប់គ្រងនិងអភិវឌ្ឍការងារអប់រំកាយនិងកីឡា នៅក្នុងក្រសួងនិងសង្គមជាតិ។

អគ្គនាយដ្ឋានកីឡា ដឹកនាំដោយអគ្គនាយកមួយរូបនិងមានអគ្គនាយករងមួយចំនួន តាមការចាំបាច់។

**មាត្រា៣៩ .-**

នាយកដ្ឋានអប់រំកាយនិងកីឡា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- អភិវឌ្ឍកីឡាជំនាញដោយសហការជាមួយសហព័ន្ធកីឡាជាតិ
- សិក្សាស្រាវជ្រាវការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា
- សហការជាមួយនឹងសហព័ន្ធកីឡាជាតិ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និងអង្គភាពពាក់ព័ន្ធលើបច្ចេកទេសកីឡាសម្រាប់ការប្រកួតក្នុងនិងក្រៅប្រទេស
- សហការរៀបចំការប្រកួតជ្រើសរើសជើងឯកទូទាំងប្រទេសជាមួយសហព័ន្ធកីឡា
- សហការជាមួយនឹងអង្គភាពពាក់ព័ន្ធលើការស្រាវជ្រាវ គ្រប់គ្រង និងផ្សព្វផ្សាយស្ថិតិ ប្រព័ន្ធទិន្នន័យព័ត៌មានអំពីវិស័យអប់រំកាយនិងកីឡា
- បំផុស ស្តារ និងអភិវឌ្ឍកីឡាប្រពៃណីជាតិ
- បំផុសសកម្មភាពអប់រំកាយនិងកីឡា ដើម្បីសុខភាពរបស់មហាជនគ្រប់ស្រទាប់
- គ្រប់គ្រងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡាជំនាញនិងកីឡាមហាជនទូទាំងប្រទេស
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានអប់រំកាយនិងកីឡា ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា៤០ .-**

នាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស និស្សិត មានតួនាទីនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងការងារអប់រំកាយនិងកីឡាសិស្ស និស្សិតគ្រប់គ្រឹះស្ថានសិក្សា
- បំផុសនិងអភិវឌ្ឍសកម្មភាពអប់រំកាយនិងកីឡាតាមគ្រឹះស្ថានសិក្សាក្នុងនិងក្រៅម៉ោងសិក្សា
- សហការជាមួយសហព័ន្ធកីឡាសិស្ស និស្សិត ដើម្បីចូលរួមប្រកួតលើឆាកអន្តរជាតិ
- រៀបចំកម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយនិងកីឡា
- រៀបចំប្រកួតកីឡាសិស្ស និស្សិត និងពិនិត្យតាមដានលើមុខវិជ្ជាអប់រំកាយនិងកីឡា
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស និស្សិត ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា៤១ .-**

មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- អភិវឌ្ឍវិស័យកីឡាជំនាញនិងកីឡាកម្រិតខ្ពស់
- គ្រប់គ្រងនិងប្រមូលផ្តុំគ្រូបង្វឹក អនុរក្ស កីឡាករ កីឡាការិនីជម្រើសជាតិគ្រប់ប្រភេទកីឡា មកធ្វើការបំប៉ន ហាត់ហ្វឹកហ្វឺន
- សហការជាមួយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជានិងអង្គភាពពាក់ព័ន្ធ ដើម្បីបញ្ជូនកីឡាករ កីឡាការិនី និងគ្រូបង្វឹកទៅចូលរួមប្រកួតអន្តរជាតិក្នុងក្របខណ្ឌជាពហុកីឡា"Games"
- បង្កើតនិងគ្រប់គ្រងមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡាតាមភូមិភាគ
- សិក្សា ស្រាវជ្រាវ ពិនិត្យ តាមដានលទ្ធផលបច្ចេកទេសកីឡាកម្រិតខ្ពស់
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

មជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា មានឋានៈស្មើនាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា៤២ .-**

វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- បណ្តុះបណ្តាលធនធានមនុស្សលើផ្នែកអប់រំកាយនិងកីឡា
- បណ្តុះបណ្តាលគ្រូអប់រំកាយនិងកីឡា
- ធ្វើវិក្រឹតការនិងពិនិត្យ តាមដាន វាយតម្លៃគ្រូអប់រំកាយនិងកីឡា
- សិក្សាស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងកីឡាជាតិនិងអន្តរជាតិ
- សម្របសម្រួលនិងសហការជាមួយនឹងនាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស និស្សិត ពាក់ព័ន្ធនឹងការងារអប់រំកាយនិងកីឡា
- អភិវឌ្ឍវិស័យកីឡាដោយសហការជាមួយនឹងសហព័ន្ធកីឡាជាតិនិងគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និងអង្គភាពពាក់ព័ន្ធ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា មានឋានៈស្មើនាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

## ជំពូកទី៩

## អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ

**មាត្រា៤៣ .-**

អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ មានតួនាទីនិងភារកិច្ចសម្របសម្រួលនិងគ្រប់គ្រងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ គោលនយោបាយ ផែនការ និងពិនិត្យ តាមដាន និងវាយតម្លៃ។

អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ ដឹកនាំដោយអគ្គនាយកមួយរូបនិងមានអគ្គនាយករងមួយចំនួនតាមការចាំបាច់។

**មាត្រា៤៤ .-**

នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ធ្វើបច្ចុប្បន្នកម្មស្ថិតិអប់រំ វិភាគ និងផលិតស្ថិតិ សូចនាករអប់រំ និងបោះពុម្ពផ្សព្វផ្សាយជាសាធារណៈ
- រៀបចំផែនទីសិក្សានិងផ្សព្វផ្សាយប្រើប្រាស់ជាសាធារណៈ
- សហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍពាក់ព័ន្ធ ដើម្បីអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា៤៥ .-**

នាយកដ្ឋានគោលនយោបាយ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំនិងសម្របសម្រួលគោលនយោបាយអប់រំ យុវជន និងកីឡា
- សិក្សា ស្រាវជ្រាវ និងតាមដានការប្រែប្រួលនិន្នាការក្នុងតំបន់និងពិភពលោក ដើម្បីកសាងគោលនយោបាយអប់រំ
- សហការជាមួយនឹងនាយកដ្ឋានពាក់ព័ន្ធនិងគ្រឹះស្ថានសិក្សានានាលើការងារស្រាវជ្រាវពាក់ព័ន្ធនឹងគោលនយោបាយអប់រំ
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍក្នុងការធ្វើបច្ចុប្បន្នកម្មគោលនយោបាយ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានគោលនយោបាយ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា៤៦ .-**

នាយកដ្ឋានផែនការ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំនិងសម្របសម្រួលផែនការអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា
- ធ្វើបច្ចុប្បន្នកម្មផែនការអប់រំនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- សម្របសម្រួលនិងកៀរគរធនធានហិរញ្ញប្បទានសម្រាប់អភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា
- សហការជាមួយនឹងអង្គភាពពាក់ព័ន្ធក្នុងការរៀបចំផែនទីសិក្សា
- សហការជាមួយនឹងស្ថាប័នជាតិនិងអន្តរជាតិ ដើម្បីអភិវឌ្ឍសមត្ថភាពស្ថាប័ននិងមន្ត្រីជំនាញផែនការអប់រំ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានផែនការ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា៤៧ .-**

នាយកដ្ឋានពិនិត្យ តាមដាន និងវាយតម្លៃ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការ កម្មវិធី គម្រោងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា
- អភិវឌ្ឍយន្តការពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការ កម្មវិធី គម្រោងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា
- រៀបចំរបាយការណ៍ស្តីពីសមិទ្ធផលការងារអប់រំ យុវជន និងកីឡា
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

នាយកដ្ឋានពិនិត្យ តាមដាន និងវាយតម្លៃ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

## ជំពូកទី១០

## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៤៨ .-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានតួនាទីនិងភារកិច្ចដូចតទៅ៖

- កំណត់នូវភាពសមស្រប គ្រប់គ្រាន់ និងការផ្តល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ផ្នែកគណនេយ្យ រដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព
- ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា ភាពច្បាស់លាស់ នៃព័ត៌មានហិរញ្ញវត្ថុនិងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់អនុលោមតាមគោលការណ៍ ផែនការ នីតិវិធីច្បាប់
- ពិនិត្យឡើងវិញលើការគ្រប់គ្រង ការថែទាំ ការពារទ្រព្យសម្បត្តិ និងធ្វើការផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិឱ្យបានត្រឹមត្រូវ
- វាយតម្លៃភាពសន្សំសំចៃ ប្រសិទ្ធភាព និងភាពផ្តល់ផលវិជ្ជមានពីការប្រើប្រាស់ធនធាន ផ្តល់អនុសាសន៍លើចំណុចខ្វះខាត ដើម្បីដោះស្រាយបញ្ហាឱ្យបានសមស្រប
- ពិនិត្យឡើងវិញលើប្រតិបត្តិការកម្មវិធីនិងគម្រោងចំណាយអភិវឌ្ឍមូលធនដើម្បីធានាថាលទ្ធផលស្របតាមកម្មវត្ថុនិងទិសដៅដែលបានកំណត់
- ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាមការិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរការទិន្នន័យសំខាន់ៗក្រោយពេលដំឡើងរួច ដើម្បីកំណត់ប្រព័ន្ធទាំងនោះឆ្លើយតបតាមគោលបំណងនិងគោលដៅដែលបានគ្រោងទុក
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុងជាមួយនឹងអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាទំហំការងារឱ្យបានគ្រប់គ្រាន់ និងកាត់បន្ថយការងារស្ទួនគ្នា
- វាយតម្លៃផែនការឬសកម្មភាពកែលម្អលើចំណុចរកឃើញរបស់សវនកម្មផ្ទៃក្នុង
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

## ជំពូកទី១១
## ខុទ្ទកាល័យ

**មាត្រា៤៩ .-**

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន ដូចមានយោងក្នុងមូលបទខាងលើ។

## ជំពូកទី១២
## អង្គភាពមូលដ្ឋាន

**មាត្រា៥០ .-**

នៅតាមរាជធានី ខេត្តនីមួយៗ មានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា ទទួលបន្ទុកអនុវត្តតួនាទីនិងមុខងាររបស់ក្រសួង។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពមូលដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី១៣
## គ្រឹះស្ថានសិក្សាស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា

**មាត្រា៥១ .-**

គ្រឹះស្ថានឧត្តមសិក្សាដែលមានចែងក្នុងមាត្រា៦នៃអនុក្រឹត្យនេះ មានមុខងាររៀបចំបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សា។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គ្រឹះស្ថានឧត្តមសិក្សាទាំងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លើកលែងតែគ្រឹះស្ថានសាធារណៈឧបនិស្ស័យរដ្ឋបាលដែលត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ជំពូកទី១៤
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា៥២ .-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី១៥
## អន្តរប្បញ្ញត្តិ

**មាត្រា៥៣ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលកំពុងអនុវត្ត ត្រូវបន្តសុពលភាពអនុវត្ត រហូតដល់មានបទប្បញ្ញត្តិថ្មីចូលមកជំនួស។

**មាត្រា៥៤ .-**

មន្ត្រីរាជការនិងសកម្មភាពការងារទាំងអស់ ដែលស្ថិតក្នុងក្របខណ្ឌនៃអង្គភាពដើមរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានផ្ទេរនិងបន្តនិរន្តរភាពឱ្យស្របតាមអនុក្រឹត្យនេះ។

## ជំពូកទី១៦

## អវសានប្បញ្ញត្តិ

**មាត្រា៥៥ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ថ្នាក់រដ្ឋបាលកណ្តាល ចាប់ពីក្រោមថ្នាក់នាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥៦ .-**

អនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥៧ អនក្រ.បក
ចុះថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០១៦ ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

# អង្គការលេខរបស់ក្រសួងអប់រំ យុវជន និងកីឡា



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៥៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .—**

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**មាត្រា២ .–**

អនុក្រឹត្យនេះ មានគោលបំណង ៖

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- រៀបចំមុខងារ និងភារកិច្ចរបស់អគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ក្នុងវិស័យទឹកស្អាត។

**មាត្រា៣ .–**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពចំណុះក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងអង្គភាពផលិត និងផ្គត់ផ្គង់ទឹកស្អាត ទាំងផ្នែកសាធារណៈ និងឯកជន ដោយគ្របដណ្តប់លើវិស័យទឹកស្អាតទីប្រជុំជន នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## បេសកកម្ម ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា៤ .–**

អគ្គនាយកដ្ឋានទឹកស្អាត ជាសេនាធិការរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានបេសកកម្មដឹកនាំ គ្រប់គ្រង និងធ្វើបញ្ញត្តកម្មការងារទឹកស្អាតទីប្រជុំជនក្នុងក្របខណ្ឌទូទាំងប្រទេស។

**មាត្រា៥ .–**

អគ្គនាយកដ្ឋានទឹកស្អាត មានមុខងារ និងភារកិច្ចដូចតទៅ៖

១. កសាងបណ្តាឯកសារគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ ស្តង់ដារបច្ចេកទេស គោលការណ៍ផ្សេងៗ សម្រាប់ដឹកនាំគ្រប់គ្រងរដ្ឋលើវិស័យទឹកស្អាត ដែលមានភារកិច្ចលម្អិត ដូចជា៖
- រៀបចំ តាក់តែង និងត្រួតពិនិត្យការអនុវត្តច្បាប់ និងបទប្បញ្ញត្តិទាំងឡាយនៃវិស័យទឹកស្អាត
- រៀបចំ តាក់តែង និងចាត់តាំងអនុវត្តគោលនយោបាយជាតិវិស័យទឹកស្អាតឱ្យមានប្រសិទ្ធភាព
- រៀបចំ កសាង និងចាត់តាំងអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការមេអភិវឌ្ឍវិស័យទឹកស្អាត
- រៀបចំ និងចាត់តាំងអនុវត្តគោលការណ៍ជំរុញការវិនិយោគវិស័យទឹកស្អាត
- រៀបចំ តាក់តែង កំណត់ស្តង់ដារបច្ចេកទេសប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដើម្បីធានាប្រសិទ្ធភាពនៅក្នុងដំណើរការផ្គត់ផ្គង់ទឹកស្អាត រួមចំណែកដល់ការលើកកម្ពស់ជីវភាពប្រជាជនដែលជាអ្នកប្រើប្រាស់
- រៀបចំ និងចាត់តាំងអនុវត្តផែនការសុវត្ថិភាពទឹក ដើម្បីធានាថា ការផ្គត់ផ្គង់ទឹកស្អាតពិតជាមានសុវត្ថិភាពគ្រប់ពេល
- រៀបចំ ដឹកនាំ កសាងផែនការរយៈពេលខ្លី មធ្យម និងវែងរបស់គ្រប់ប្រតិបត្តិករទឹកស្អាត ដើម្បីសម្រេចឱ្យបានទិសដៅរបស់រាជរដ្ឋាភិបាលលើវិស័យទឹកស្អាត
- សិក្សា ស្រាវជ្រាវ លើកគម្រោងវិនិយោគ ដើម្បីស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា សំដៅអភិវឌ្ឍ

វិស័យទឹកស្អាតឱ្យបានរីកចម្រើនឆាប់រហ័ស រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងការអភិវឌ្ឍឿនសេដ្ឋកិច្ចជាតិ

- ដឹកនាំត្រួតពិនិត្យគ្រប់ប្រតិបត្តិការទឹកស្អាតទីប្រជុំជន ដើម្បីធានាសុខមាលភាពប្រជាជន អ្នកប្រើប្រាស់ និងការពារបរិស្ថានសង្គម
- រៀបចំចងក្រងឯកសារ បទពិសោធន៍នានា និងចាត់តាំងការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់គ្រប់ប្រតិបត្តិករផលិត និងផ្គត់ផ្គង់ទឹកស្អាត ដើម្បីរួមចំណែកដល់ប្រសិទ្ធភាពការងារផ្គត់ផ្គង់ទឹកស្អាត។

២. អនុវត្តនីតិវិធីនៃការផ្តល់ប្រកាសការអនុញ្ញាតឱ្យធ្វើអាជីវកម្មដល់គ្រប់ប្រតិបត្តិករសាធារណៈ ឬឯកជនចម្រុះរដ្ឋ ឬឯកជន ដោយឈរលើមូលដ្ឋាននៃបណ្តាឯកសារគតិយុត្តជាធរមាន ដែលមានភារកិច្ចលម្អិត ដូចជា៖

- សិក្សា វិភាគ វិនិច្ឆ័យ ដើម្បីផ្តល់យោបល់ទៅផ្នែកពាក់ព័ន្ធលើឯកសារសិក្សាសមិទ្ធិលទ្ធភាព ដែលបានសិក្សា និងស្នើឡើងដោយវិនិយោគិន ឬប្រតិបត្តិករផលិត និងផ្គត់ផ្គង់ទឹកស្អាត
- សិក្សា វិភាគ វិនិច្ឆ័យ ដើម្បីផ្តល់យោបល់ទៅផ្នែកពាក់ព័ន្ធលើឯកសារស្នើសុំប្រកាសអនុញ្ញាតជំនួស ដែលបានស្នើឡើងដោយប្រតិបត្តិករផលិត និងផ្គត់ផ្គង់ទឹកស្អាត
- ធ្វើបញ្ញត្តកម្មសេដ្ឋកិច្ច និងសង្គម ពិសេសបញ្ញត្តកម្មថ្លៃលក់ទឹក ដើម្បីធានាការពារផលប្រយោជន៍គ្រប់ភាគីពាក់ព័ន្ធឱ្យមានសមធម៌ជាចាំបាច់ សំដៅជួយដល់ភាគីវិនិយោគិនអាចទទួលបានការបង្វិលទុនវិញដោយមានអត្រាចំណេញសមស្រប ទៅតាមបរិបទនៃទីផ្សារជាក់ស្តែង ភាគីអ្នកទទួលសេវាទឹកស្អាតទទួលបាននូវសេវាដែលមានគុណភាព និងថ្លៃសមស្រប និងភាគីរដ្ឋាភិបាលទទួលបានការសម្រេចនូវគោលនយោបាយរបស់ខ្លួនសម្រាប់វិស័យទឹកស្អាត។
- សិក្សា កសាងកញ្ចប់ព័ត៌មាន ឯកសារដេញថ្លៃ ដើម្បីចាត់តាំងធ្វើការដេញថ្លៃជាសាធារណៈ ក្នុងការផ្តល់ប្រកាសអនុញ្ញាតប្រកួតប្រជែង
- ធ្វើការផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ អំពីថ្លៃលក់ទឹក និងថ្លៃសេវាផ្សេងៗ ដែលក្រសួងឧស្សាហកម្ម និងសិប្បកម្មបានសម្រេច ព្រមទាំងចុះធ្វើការបកស្រាយករណីនីមួយៗតាមការចាំបាច់
- ចូលរួមធ្វើអធិការកិច្ចបណ្តាមូលដ្ឋានផ្តល់សេវាទឹកស្អាត តាមកម្មវិធី ឬតាមពាក្យបណ្តឹងតវ៉ា ឬ តាមការចាំបាច់។

**មាត្រា៦ .—**

អគ្គនាយកដ្ឋានទឹកស្អាត ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជាជំនួយការ។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

អង្គការលេខរបស់អគ្គនាយកដ្ឋានទឹកស្អាត ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៧ ._**

អគ្គនាយកដ្ឋានទឹកស្អាត មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម ៖

១. នាយកដ្ឋានសរុប និងព័ត៌មាន

២. នាយកដ្ឋានផែនការ និងគ្រប់គ្រងទិន្នន័យ

៣. នាយកដ្ឋានគោលនយោបាយទឹកស្អាត

៤. នាយកដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង

៥. នាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត

**មាត្រា៨ ._**

ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពនានា ក្រោមឱវាទរបស់អគ្គនាយកដ្ឋានទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**មាត្រា៩ ._**

នាយកដ្ឋានសរុប និងព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទឹកស្អាត លើការងាររដ្ឋបាល គ្រប់គ្រង អភិវឌ្ឍធនធានមនុស្ស និងគណនេយ្យ។

នាយកដ្ឋានផែនការ និងគ្រប់គ្រងទិន្នន័យ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទឹកស្អាត លើការងារផែនការ និងការគ្រប់គ្រងទិន្នន័យ ក្នុងវិស័យទឹកស្អាតទីប្រជុំជននៅទូទាំងប្រទេស។

នាយកដ្ឋានគោលនយោបាយទឹកស្អាត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទឹកស្អាត លើការងាររៀបចំគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យទឹកស្អាតទីប្រជុំជននៅទូទាំងប្រទេស។

នាយកដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទឹកស្អាត លើការងារបច្ចេកទេស និងការងារកសាង គ្រប់គ្រង និងអនុវត្តគម្រោង ក្នុងវិស័យទឹកស្អាតទីប្រជុំជននៅទូទាំងប្រទេស។

នាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទឹកស្អាត លើការងារបញ្ញត្តកម្មក្នុងវិស័យទឹកស្អាតទីប្រជុំជននៅទូទាំងប្រទេស។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា១០ ._**

អនុក្រឹត្យនេះ បំពេញបន្ថែមឱ្យអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**មាត្រា១១ ._**

នាយកដ្ឋានទឹកស្អាត ដែលបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ

ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល</u> ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**អង្គការលេខរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

ភ្ជាប់ជាឯកសារឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៣

និងជាឯកសារឧបសម្ព័ន្ធបំពេញបន្ថែម តាមអនុក្រឹត្យលេខ...១៥៧.......អនក្រ.បក ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៦



**អង្គការលេខរបស់អគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

ភ្ជាប់ជាឯកសារឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ១៥៧ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៦



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ប្រើប្រាស់ និងជាំងុះជាក់ស្តែង នៅក្នុងបុរីសណ្ឋាគារអង្គរសៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញាឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ចុះថ្ងៃទី២២ខែមករាឆ្នាំ១៩៩៩ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួន នៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៥ ស្តីអំពីបុរីសណ្ឋាគារ
- បានឃើញអនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការពង្រីកផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**មាត្រា១** : អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត នៅលើទីតាំងដីបុរីសណ្ឋាគារ ដែលមានចែងក្នុងអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៥ ស្តីអំពីបុរីសណ្ឋាគារ និងអនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការពង្រីកផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរា។

**មាត្រា២** : ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋវិញចំពោះក្បាលដីទាំងឡាយណា ដែលអាជ្ញាធរអប្សរាមិនទាន់បានដោះស្រាយគោលនយោបាយ ហើយបានកាន់កាប់អាស្រ័យផលជាក់ស្តែង។

**មាត្រា៣** : ប្រគល់ជូនអាជ្ញាធរអប្សរាគ្រប់គ្រងនូវផ្ទៃដីទាំងឡាយណា ដែលបានដោះស្រាយគោលនយោបាយរួចហើយ។

**មាត្រា៤** : អាជ្ញាធរខេត្ត និងអជ្ញាធរអប្សរា ត្រូវសហការអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាព។

**មាត្រា៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងអគ្គនាយកអាជ្ញាធរអប្សរា ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៩១៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## សម្រេច

**មាត្រា១.** បំពាក់ មេដាយសុវត្ថារា ថ្នាក់ **អស្សឫទ្ធិ** ជូនមន្ត្រីរាជការ ចំនួន១៥រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច និងចូលរួមជួយរៀបចំប្រព័ន្ធទុយោទឹកស្អាត នៅក្រុងកំពង់ចាម កន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក | វ៉ា សំឌិក | អនុប្រធានអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ២-លោក | តេង សាវឿន | អនុប្រធានអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៣-លោក | ជិន ទ្រី | ប្រធានស្ថានីយ៍ទី១ នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៤-លោក | វ៉ា សាវឿន | ប្រធានក្រុម នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៥-លោក | ឈិត ចំរើន | អនុប្រធានផ្នែក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៦-លោក | ទ្រី ទាងហុង | ប្រធានផ្នែក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៧-លោក | ប៊ាង វិបុល | ប្រធានបញ្ជាបង់ប្រាក់ នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៨-លោក | ប៊ន ប៉េងអាន | ប្រធានក្រុម នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៩-លោក | អ៊ិត សំណាង | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |

| | | |
|---|---|---|
| ១០-លោក | អ៊ុក សុផល | ប្រធានក្រុម នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១១-លោក | អ៊ីន គុងអ៊ាន | ប្រធានស្ថានីយ៍ទី២ នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១២-លោក | ស៊ា ប៊ុននាយ | ប្រធានឃ្លាំង នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១៣-លោក | ឈាវ ច័ន្ទវីរ៉ា | បេឡាធិកា នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១៤-លោក | ប៉ាង ឧត្តម | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១៥-លោក | ស៊ា គីមហ៊ាត់ | ប្រធានរោងចក្របឹងកុក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨១៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ចំនួន១៩រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច និងចូលរួមជួយរៀបចំប្រព័ន្ធទុយោទឹកស្អាត នៅក្រុងកំពង់ចាម កន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក | ទឹម មិថុនា | ប្រធានក្រុម នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ២-លោក | មុជ ប្រាក់ | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៣-លោក | យឹម សុធី | ប្រធានផ្នែក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៤-លោកស្រី | ងួន វ៉ាន់ច័ន្ទតារា | អនុប្រធានផ្នែក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៥-លោកស្រី | ប៊ិញ លីដា | ប្រធានក្រុម នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៦-លោកស្រី | វ៉ា សុភ័ក្រ្ត | ប្រធានក្រុម នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៧-លោកស្រី | ខោល មណីរ័ត្ន | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៨-លោកស្រី | ហាវ ធារី | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ៩-លោក | ពុធ ចាន់ថន | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១០-លោក | វ៉េន វុធ | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១១-លោក | ឆាន គីមឈុន | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |

| | | | |
|---|---|---|---|
| ១២-លោក | ឡេង | សីហា | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១៣-លោក | ឈឿន | គឿន | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១៤-លោក | អ៊ុំ | ឡង់ហេង | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១៥-លោក | ឈាង | ឈៀក | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១៦-លោក | តន | តុន | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១៧-លោក | វ៉ន | សាវ៉ាន់ | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១៨-លោក | អែម | ផានិត | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |
| ១៩-លោក | សាយ | សុភា | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១._

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជន និងផ្តល់ជូនមន្ត្រីរាជការចំនួន ០៩រូប ដែលបានលះបង់កម្លាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋានលើគ្រប់វិស័យអោយមានការរីកចម្រើនគួរជាទីមោទនៈ ស្ថិតនៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ០៧ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណ **សេង ថន** ព្រះចៅអធិការវត្តឈូក

២-លោក **សុខ គឿម** នាយកអនុវិទ្យាល័យស្មោង

៣-លោក **ឈិត ដានី** អនុប្រធានសមាគមអាចារ្យខ្មែរ ក្រុងព្រៃវែង

៤-លោក **ឆាន សុផា** ជិទប់ទី១ ឃុំស៊ាងឃ្វាង

៥-លោក **នាង វីឆាត** សប្បុរសជននៅរាជធានីភ្នំពេញ

៦-លោក **សួន លីហួត** សប្បុរសជននៅរាជធានីភ្នំពេញ

៧-លោកវរសេនីយ៍ត្រី **ឃឿន សុវណ្ណ** នាយរងការិយាល័យនគរបាលការពារ និងអន្តរាគមន៍ អត្តលេខ ១១២៤៥

**ខ- មេដាយមុនីសារាភ័ណ្ឌថ្នាក់អស្សឫទ្ធិចំនួន ០២ គ្រឿង ផ្តល់ជូន :**

១-លោកអនុសេនីយ៍ឯក **ម៉េង សារឿង** អនុប្រធានផ្នែកនគរបាលការពារ អត្តលេខ ៥៧២៧១

២-លោកអនុសេនីយ៍ទោ **អ៊ឹម ចាន់ដារ៉ា** នាយផ្នែកនៃស្នងការដ្ឋាននគរបាលខេត្តកំពត អត្តលេខ ៧១២៤៩

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ.ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
-រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:**......៥៧១.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១ ._

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ២២ រូប ដែលបានលះបង់កម្លាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋានលើគ្រប់វិស័យអោយមានការរីកចម្រើនគួរជាទីមោទនៈ ស្ថិតនៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក-  មេដាយមាសស្ថាបនាជាតិចំនួន ១២ គ្រឿង  ប្រគេន  និងផ្តល់ជូន :**

១-ព្រះតេជគុណ **មូ  រ៉ា**  ព្រះចៅអធិការវត្តមុនីរត្ន័

២-ព្រះតេជគុណ **យាន  យ៉ាន**  ព្រះចៅអធិការវត្តបុស្ស

៣-ព្រះតេជគុណ **ហែម  សាវី**  ព្រះចៅអធិការវត្តសង្កែរ

៤-ព្រះតេជគុណ **ហែម  ហេង**  ព្រះចៅអធិការវត្តពោធិ៍អណ្តែត

៥-ព្រះតេជគុណ **ពៅ  រតនា**  ព្រះចៅអធិការវត្តក្របៅថ្មី

៦-លោកឧត្តមសេនីយ៍ត្រី **សេង  ឫទ្ធី**  អនុប្រធាននាយកដ្ឋានច្រកទ្វារទី១ អត្តលេខ ២២១៦

៧-ឧបាសក **ហេ យាប** អាចារ្យវត្តក្របៅថ្មី

៨-ឧបាសក **ឆេព ស៊ុន** អាចារ្យវត្តក្របៅថ្មី

៩-ឧបាសក **ចៅ ឌិន** គណៈកម្មការវត្តគុំនុំ

១០-ឧបាសក **ហោម ប៊ុនហ៊ាប** គណៈកម្មការវត្តគុំនុំ

១១-លោក **ផល សុភាព** សប្បុរសជននៅរាជធានីភ្នំពេញ

១២-លោកអនុសេនីយ៍ត្រី **ទ្រី សុវណ្ណចាន់ធារិទ្ធ** នាយរងផ្នែក នាយកដ្ឋានរដ្ឋបាលសរុប អត្តលេខ ៧៧៦៩២

**ខ- មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៤ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណ **អែ ចេន** ព្រះចៅអធិការវត្តឫស្សីជ័យឧត្តម

២-ឧបាសក **ជា ម៉ៃ** គណៈកម្មការវត្តពោធិ៍អណ្តែត

៣-ឧបាសក **សៀវ សន** អាចារ្យវត្តពោធិ៍អណ្តែត

៤-ឧបាសក **ជួន មួន** អាចារ្យវត្តពោធិ៍អណ្តែត

**គ- មេដាយសំរិទ្ធិស្ថាបនាជាតិចំនួន ០៦ គ្រឿង ផ្តល់ជូន :**

១-ឧបាសក **សួន ណើង** គណៈកម្មការវត្តពោធិ៍អណ្តែត

២-ឧបាសក **សោម រ៉េត** គណៈកម្មការវត្តពោធិ៍អណ្តែត

៣-ឧបាសក **ស៊ឹម ឃ្លោក** គណៈកម្មការវត្តពោធិ៍អណ្តែត

៤-ឧបាសក **ទន់ តែម** គណៈកម្មការវត្តពោធិ៍អណ្តែត

៥-ឧបាសិកា **យ៉ាន់ ឡោ** យាយជីវត្តពោធិ៍អណ្តែត

៦-ឧបាសិកា **ផន នឿន** យាយជីវត្តពោធិ៍អណ្តែត

មាត្រា ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** [illegible] អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ផ្តល់ជូនមន្ត្រីរាជការចំនួន ១០រូប ដែលបានលះបង់កម្លាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋានលើគ្រប់វិស័យអោយមានការរីកចម្រើនគួរជាទីមោទនៈ ស្ថិតនៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

១-លោកអនុសេនីយ៍ទោ **សំនៀង បញ្ញា** នាយរងផ្នែកស្ថិតិនគរបាលស្រុកកំចាយមារ អត្តលេខ ៥៦៦៦៨

២-លោកអនុសេនីយ៍ត្រី **ជាង ច័ន្ទណារិទ្ធ** ជំនួយការប្រធាននាយកដ្ឋានច្រកទ្វារទី១ អត្តលេខ ៧៣២៥០

៣-លោក **ជា កែវសុជាតា** មន្ត្រីនាយកដ្ឋានសោតទស្សន៍ នៃក្រសួងព័ត៌មាន

៤-លោក **មឿន វុត្ថា** មន្ត្រីកិច្ចសន្យានាយកដ្ឋាននីតិកម្ម នៃក្រសួងព័ត៌មាន

៥-លោក **ខិត គីម** មន្ត្រីកិច្ចសន្យានាយកដ្ឋាននីតិកម្ម នៃក្រសួងព័ត៌មាន

៦-លោក **គៅ សីហា** មេធាវីពេញសិទ្ធិរាជធានីភ្នំពេញ

៧-លោក **ហែម សុចិត្រ** មេធាវីពេញសិទ្ធិរាជធានីភ្នំពេញ

៨-លោក **ពែត រួន** សមាជិកក្រុមប្រឹក្សាឃុំស្មោងខាងត្បូង

៩-លោកស្រី **ឌឹម  តុល**  ជំទប់ទី១ឃុំដូនកឹង

១០-លោក **ប៊ូ  ម៉ាន់នី**  ប្រធានមណ្ឌលសុខភាពដូនកឹង

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ  រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ  កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៧៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ផ្តល់ជូនលោក **ផាតឆ័រ ហ្គូតូ ហ្វូមីអូ** ( Mr. PATHER GOTO FUMIO) សប្បុរសជនជនជាតិជប៉ុន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងអគារសិក្សា ០១ខ្នង មាន ០៤បន្ទប់ នៅ**សាលាបឋមសិក្សាអូរដំបង២** ស្ថិតនៅក្នុងឃុំអូរដំបង២ និងអគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ នៅ**សាលាបឋមសិក្សាអន្លង់ល្វា** ស្ថិតនៅក្នុងឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង ។

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨៧៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ** ចំនួន ០២គ្រឿង ជូនថ្នាក់ដឹកនាំនៃវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កន្លងមកដូចមានរាយនាមខាងក្រោម៖

១-លោកបណ្ឌិត **ម៉ាតស៊ូ ម៉័រែល** (Matthew Morell) អគ្គនាយកនៃវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ(IRRI)

២-លោកបណ្ឌិត **វីប្រ៊ូស ជេ តូលេនទីណូ** (V. Bruce J. Tolentino) អគ្គនាយករងនៃវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ(IRRI)

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:**...៥៧៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេសចំនួន ១៤ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ***វត្តសុវណ្ណមរកត*** ស្ថិតនៅក្នុងឃុំកំពង់ចំលង និងនៅ***វត្តព្រែកជ្រូក*** ស្ថិតនៅក្នុងឃុំបាក់ដាវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ១២ គ្រឿង ផ្តល់ជូន :**

| | | |
|---|---|---|
| ១-ឧបាសិកា **ឡុង ហ៊ុន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៥.០០០ ដុល្លារ |
| ២-ឧបាសិកា **ម៉េង ឡេក** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ១៥.០០០ ដុល្លារ |
| ៣-ឧបាសិកា **អ៊ឹង អ៊ីមលន់** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ៤-លោកជំទាវ **ជា សៀមអៀង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ៥-ឧបាសក **អ៊ី ប៊ូ** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ៦-ឧបាសក **ចាន់ សុន** | គណៈកម្មការវត្តព្រែកជ្រូក | ថវិកាចំនួន ១១.០០០ ដុល្លារ |

| | | | |
|---|---|---|---|
| ៧-ឧបាសិកា | **អ៊ុំ ឈាងឡាំង** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១០.៨០០ ដុល្លារ |
| ៨-លោក | **តែ ចេងហួត** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ៩-លោក | **ចែ អួន** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ១០-ឧបាសក | **គង់ ម៉ៅ** | គណៈកម្មការវត្តព្រែកជ្រូក | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ១១-ឧបាសក | **អ៊ឹម អឿន** | គណៈកម្មការវត្តព្រែកជ្រូក | ថវិកាចំនួន ១០.២០០ ដុល្លារ |
| ១២-លោក | **ឡេង ឌី** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ១០.០០០ ដុល្លារ |

**ខ_ មេដាយប្រាក់ស្ថាបនាជាតិចំនួន ០២ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក | **ឆេព រិទ្ធី** | សប្បុរសជនរាជធានីភ្នំពេញ | ថវិកាចំនួន ៥.១៥០ ដុល្លារ |
| ២-លោក | **ទ៉ាន់ លឿន** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៥.១០០ ដុល្លារ |

**មាត្រា ២ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧/ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨២៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់**ធិបឌិន្ទ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ**វត្តសុវណ្ណមរកត** ស្ថិតនៅក្នុងឃុំកំពង់ចំលង និងនៅ**វត្តព្រែកជ្រូក** ស្ថិតនៅក្នុងឃុំបាក់ដាវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

១-ព្រះតេជគុណព្រះកេស្យធម្មោ**អ៊ីក ទាសនា** ព្រះចៅអធិការវត្តព្រែកជ្រូក បច្ច័យចំនួន ៦៤.៦០០ ដុល្លារ
២-លោក **ឌួន គឹមសាន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៣៥.៤០០ ដុល្លារ
៣-លោកស្រី **ខេង ស្រីនាង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៣៤.៩០០ ដុល្លារ
៤-លោក **យោន គេង** មេឃុំបាក់ដាវ ថវិកាចំនួន ៣៤.៥០០ ដុល្លារ

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ..៧៧១..សសរ..

# សេចក្តីសម្រេច
## ស្តីពី
## ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងឯកឧត្តម **ឯកឧត្តម លី ផល្លា** រដ្ឋលេខាធិការក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តក្រចេះ ។

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តក្រចេះ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០១៦

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**សម្តេចក្រឡាហោម ស ខេង**

<u>*កន្លែងទទួល:*</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧២៣ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំង អនុប្រធាន ក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.**_

ត្រូវបានតែងតាំងអនុប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តកំពតដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ខួយ យុនហ៊ួរ** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ២- ឯកឧត្តម **ចាន់ ចេស្តា** | អភិបាលនៃគណៈអភិបាលខេត្តកំពត | អនុប្រធានអចិន្ត្រៃយ៍ |

**ប្រការ២.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលខេត្តកំពត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០១៦

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៧៤ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបំពេញបន្ថែម និងផ្លាស់ប្តូរសមាជិកក្រុមការងារ ថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១.**_

ត្រូវបានផ្លាស់ប្តូរឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ពីសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តប៉ៃលិន មកជាសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកណ្តាល ។

**ប្រការ២.**_

ត្រូវបានបំពេញបន្ថែម ឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារជាសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តប៉ៃលិន ។

**ប្រការ៣.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តកណ្តាល រដ្ឋបាលខេត្តប៉ៃលិន និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០១៦

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**សម្តេចក្រឡាហោម ស ខេង**

*កន្លែងទទួល:*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...៥៧២០....សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦

## ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួង រៀបចំនីតិវិធីគ្រប់គ្រងចំណូលពីកម្រៃសេវាធ្វើដំណើរ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នសដែលប្រកាសឱ្យប្រើ ១៩៩៦ខែមករា ឆ្នាំ ២៤ចុះថ្ងៃទី ១៥/០១៩៦/រកម/ច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង រៀបចំនីតិវិធីគ្រប់គ្រងចំណូលពីកម្រៃសេវាធ្វើដំណើរ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ជួ ទិចិត្ត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- | ឯកឧត្តម **ជា ចូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- | ឯកឧត្តម **ស ថេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- | ឯកឧត្តម **សយ សុខាន់** | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| ៥- | ឯកឧត្តម **នេត មុន្នី** | អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ ក សហវ | សមាជិក |
| ៦- | ឯកឧត្តម **សេង សន្តា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៧- | ឯកឧត្តម **សៅ សុភាព** | នាយកខុទ្ទកាល័យក្រសួងបរិស្ថាន | សមាជិក |
| ៨- | ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ឹម យ៉ាន** | អគ្គស្នងការរងនគរបាលជាតិ នៃក្រសួងមហាផ្ទៃ | សមាជិក |

៩- ឯកឧត្តម **ខូច សូវៀត** ជំនួយការអមក្រសួងបរិស្ថាន សមាជិក

១០- លោក **អូន ប៊ុនហាក់** អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ ក សហវ សមាជិក

១១- លោក **សៀក សុភ័ក** អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ ក សហវ សមាជិក

១២- លោក **យូ ពិសី** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល សមាជិក

១៣- កញ្ញា **គង់ រ័ត្នលំអង** អគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ សមាជិក

១៤- លោកឧត្តមសេនីយ៍ទោ **ឡោ សុខឡេង** ស្នងការ នៃស្នងការដ្ឋានហិរញ្ញកិច្ច និងភស្តុភារ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ សមាជិក

១៥- លោក **ម៉ាន់ ចន្ទី** ប្រធាននាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

១៦- លោកស្រី **យ៉យ ច័ន្ទទុត្ថា** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៧- លោក **តូ សុភ័ណ្ឌ** ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល សមាជិក

១៨- លោក **ហ៊ត់ ឆានី** អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ ក សហវ សមាជិក

**ប្រការ២ .-**

ក្រុមការងារអន្តរក្រសួង មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ធ្វើការសិក្សា និងរៀបចំនីតិវិធីប្រមូល និងគ្រប់គ្រងចំណូលពីកម្រៃសេវាធ្វើដំណើរ ដែលត្រូវប្រមូលពីភ្ញៀវទេសចរជាតិ និងអន្តរជាតិ
- ធ្វើការសិក្សាឱ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ដោយមានការជួបពិភាក្សាជាមួយសាមីក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាឱ្យកិច្ចដំណើរការប្រមូល និងគ្រប់គ្រងចំណូលនេះ មានភាពរលូន
- ធ្វើរបាយការណ៍ និងផ្តល់យោបល់អំពីជម្រើសនានាដែលពាក់ព័ន្ធនឹងនីតិវិធីនៃការប្រមូល និងការគ្រប់គ្រងចំណូលពីកម្រៃសេវាធ្វើដំណើរ ដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ សម្រេច ឬ ផ្តល់ការណែនាំ។

**ប្រការ៣ .-**

សមាសភាពនៃក្រុមការងារអន្តរក្រសួង ដែលមានចែងក្នុងប្រការ ១ នៃប្រកាសនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ឯកឧត្តមប្រធានក្រុមការងារ។

**ប្រការ៤ .-**

ប្រកាសលេខ ២៩១ សហវ.ចមព ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំនីតិវិធីប្រមូល និងគ្រប់គ្រងចំណូលពីកម្រៃសេវាធ្វើដំណើរ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ